សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការស៊ើបអង្កេតបទល្មើស
# ព្រហ្មទណ្ឌដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ល. លាខ វិសាល**

**ក. ឈឿន ស្រីល័ក្ខ**

ដោយសាស្ត្រាចារ្យណែនាំ

លោក **ជួន ប៊ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **លាង វិសាល** និងនាងខ្ញុំឈ្មោះ **ឈឿន ស្រីល័ក្ខ** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រជំនាន់ទី១៩ ឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះ ៖

- លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើតដល់រូបកូនទាំងពីរនិងខិតខំចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានរូបកូនទាំងពីរ ដោយបានជួយទំនុកបម្រុងកូនឲ្យបានទទួលការអប់រំដ៏ខ្ពង់ខ្ពស់រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យគួរជាទីមោទកភាព។
- លោកពូអ្នកមីងទាំងអស់ ដែលបានជួយទំនុកបម្រុងទាំងផ្នែកស្មារតី ដោយផ្តល់នូវការលើកទឹកចិត្តដល់រូបខ្ញុំបាទ និងនាងខ្ញុំឲ្យខិតខំប្រឹងប្រែងរៀនសូត្រ រហូតឈានដល់ការបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រដល់សព្វថ្ងៃនេះ។
- បងប្រុស និងបងស្រីរបស់យើងខ្ញុំជាពិសេស ដែលបានជួយទំនុកបម្រុងទាំងថវិកាមួយចំនួនធំ ព្រមទាំងផ្នែកសម្ភារសិក្សា និងសម្ភារកុំព្យូទ័រទាំងក្នុងការសិក្សាព្រមទាំង ក្នុងពេលវេលា ធ្វើសារណាបញ្ចប់ឆ្នាំសិក្សានេះផងដែរ។
- យើងខ្ញុំសូមគោរពថ្លែងអំណរគុណបងប្រុស **ហ៊ុន ម៉ាណែត** ដែលជាប្រធានសមាគមន៍អាហារបករណ៍សម្តេចអគ្គមហាសេនាបតី **តេជោ ហ៊ុន សែន** និងកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** ដែលបានផ្តល់ជាអាហារបករណ៍អោយរូបនាងខ្ញុំបានរៀនសូត្រក្នុងរយៈពេលបួនឆ្នាំ ដោយជោគជ័យ និងទទួលបានការយកចិត្តទុកដាក់ពីបងបងដែលជាដំណាងជំនួសមុខបងប្រុស **ហ៊ុន ម៉ាណែត។**
- សូមថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** ជាសកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ។
- សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់រូបខ្ញុំបាទ និងនាងខ្ញុំ។
- សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យណែនាំ លោក **ជួន ម៉ុនធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំព្រមទាំងជួយសម្រួល និងកែប្រែសារណារបស់រូបខ្ញុំទាំងពីរនាក់ ជាចុងក្រោយខ្ញុំបាទ-នាងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធទាំងអស់ សូមជួយតាមថែរក្សាអស់លោក និងអ្នកមានគុណទាំងឡាយឲ្យជួបប្រទះតែ សេចក្តីសុខ សេចក្តីចម្រើន គ្រប់ពេលវេលាកុំបីឃ្លាង ឃ្លាតឡើយ

# អារម្ភកថា

សារណាមួយនេះ គឺជាជំនួយទៅដល់អ្នកដែលមានបំណងចង់សិក្សាអំពីវិស័យនីតិសាស្ត្រ ជាពិសេសនោះ គឺមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ មន្ត្រីអនុវត្តច្បាប់ និង និស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផ្ទាល់តែម្តង។ ស្នាដៃនេះនឹងចូលរួមចំណែកមួយ ក្នុងការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសជាតិ ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌តាមរយៈខ្លឹមសារនៃសារណា ដែលបង្ហាញជូនជនរួមជាតិ និងសាធារណជន នូវមតិទូទៅអំពីគោលបំណង ឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការពុះពារបម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញឱ្យបានច្បាស់អំពីចក្ខុវិស័យពាក់ព័ន្ធនឹងយុត្តិធម៌ដើម្បីបន្តស្ពារ និងការពារមាតុភូមិឱ្យបានរុងរឿងនៃយើងឲ្យឆ្ពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរ ដែលចង់បាននូវភាពយុត្តិធម៌។

គោលបំណងក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺចង់ឱ្យមានការរីកចម្រើននៅក្នុងវិស័យច្បាប់ទាក់ទងនឹងផ្នែកព្រហ្មទណ្ឌ ក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ពីព្រោះនៅក្នុងដំណាក់កាលមួយនេះ គឺពឹងផ្អែកទាំងស្រុង ទៅលើសមត្ថភាព និងបច្ចេកទេស ឬ ជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ការ និងបង្ក្រាបបទល្មើស ដែលបានកើតមានឡើងនានា និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសង្គមកុំឱ្យមានភាពវឹកវរ ដើម្បីជៀសវាងកុំឱ្យមានភាពអសកម្មនៅក្នុងសង្គមជាតិ។

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានព្យាយាមធ្វើដោយយកចិត្តទុកជាអតិបរមា យ៉ាងណាធ្វើឱ្យសារណានេះ ទុកជាផលប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវរបស់ពលរដ្ឋខ្មែរគ្រប់រូប មន្ត្រីនគរបាល ដែលបានទទួលនូវនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬ ជាភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទា ជាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន ពិសេសនិស្សិតជំនាន់ក្រោយ ដែលមានបំណងស្វែងយល់អំពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។

ដោយសារណានេះជាស្នាដៃដំបូងរបស់ខ្ញុំបាទនាងខ្ញុំហេតុនេះ យើងខ្ញុំបានជឿជាក់ថា អាចមាន ភាពចន្លោះប្រហោង និងមានកំហុសខ្លះៗជាក់ជាមិនខានឡើយ។ ដូច្នេះខ្ញុំបាទនាងខ្ញុំរង់ចាំទទួលដោយក្តីសោមនស្សនូវរាល់ការរិះគន់ដើម្បីកែលម្អ ក្នុងន័យស្ថាបនាចំពោះស្នាដៃនេះគ្រប់ពេលវេលា។ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតដល់ជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់ជំនឿនិងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សមាសសភាពរបស់នគរបាលយុត្តិធម៌**

**ផ្នែកទី១ មន្ត្រីនគរបាលយុត្តិធម៌** ........ ៤

**កថាខណ្ឌទី១ ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌** ........ ៤

**១.១ ការទទួលបានតាមរយៈការប្រឡងប្រជែង** ........ ៤

១.១.១ លក្ខខណ្ឌដើម្បីប្រឡងសញ្ញាបត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌ ........ ៥

ក. មន្ត្រីនគរបាលជាតិ ........ ៥

ខ. នាយទាហាន នៃកងរាជអាវុធហត្ថ ........ ៥

១.១.២ បែបបទនៃកាប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ........ ៦

ក. វិញ្ញាសាប្រឡង ........ ៦

ខ. គណៈមេប្រយោគ ........ ៦

**១.២ ការទទួលបានតាមរយៈឋានន្តរស័ក្តិ និងមុខងារ** ........ ៧

១.២.១ អភិបាល និងអភិបាលរង ........ ៧

១.២.២ មេឃុំ និងចៅសង្កាត់ ........ ៧

១.២.៣ ប្រធាន និងអនុប្រធាននាយកដ្ឋាន ការិយាល័យ ផ្នែក ប៉ុស្តិ៍ និងអង្គភាពផ្សេងទៀត ........ ៧

១.២.៤ ស្នងការ និងស្នងការរងនគរបាល ........ ៩

១.២.៥ អធិការ និងអធិការរងនគបាល ........ ៩

១.២.៦ មេបញ្ជាការ និងមេញ្ជាការរងនៃកងរាជអាវុធហត្ថ ........ ៩

**១.៣ ការទទួលបានដោយស្វ័យប្រវត្តិ** ........ ៩

១.៣.១ សម្រាប់នាយទាហាន នៃកងរាជអាវុធហត្ថ ........ ៩

១.៣.២ សម្រាប់នាយនគរបាលជាតិ ........ ១០

**កថាខណ្ឌទី២ ការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌** ........ ១០

**២.១ បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌** ........ ១០

**២.២ សេចក្តីសម្រេចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌** ........ ១១

**កថាខណ្ឌទី៣ សម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌** ........ ១១

៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌........................................................១១
៣.២ អញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌.....................................................................១១
**កថាខណ្ឌទី៤ កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងពេលអនុវត្តមុខងារ**..................១១
៤.១ នីតិវិធីខាងវិន័យ ...................................................................................................................១១
៤.២ ទណ្ឌកម្មចំពោះមន្ត្រីនគរបាលយុត្តិធម៌ ...............................................................................១២
ក. ទណ្ឌកម្មខាងវិន័យ....................................................................................................................១២
ខ. ការហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌..............................................១២
**ផ្នែកទី២ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទា ពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន**...............................................................១៣
**កថាខណ្ឌទី១ ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន**. ១៣
១.១ តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ..... ១៤
១.២ តាមរយៈច្បាប់ស្តីពីព្រៃឈើ............................................................................................................១៤
**កថាខណ្ឌទី២ ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត**...១៤
២.១ បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំង .................................................................១៤
២.២ សេចក្តីសម្រេចក្នុងការតែងតាំង ..................................................................................................១៥
**កថាខណ្ឌទី៣ សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត**.......................១៥
៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថ ...............................................................................................................១៥
៣.២ នត្ថិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ដទៃទៀត...........................................................................................................................................១៦
**កថាខណ្ឌទី៤ កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ក្នុងពេលអនុវត្តមុខងារ**............................................................................................................១៦
៤.១ នីតិវិធីខាងវិន័យ .........................................................................................................................១៦
៤.២ ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាកងារសាធារណៈដទៃទៀត ........................................ ១៧

## ជំពូកទី២

## ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១ សិទ្ធិអំណាចនៅក្នុងការស៊ើបអង្កេត**...............................................................២៤
**កថាខណ្ឌទី១ ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង**......................................២៤
១.១ និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង.............................................................................២៤
១.២ វិធានការស្រាវជ្រាវ.........................................................................................................................២៨

១.២.១ វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង............................២៩
១.២.២ ការឆែកឆេរ ........................................................................................២៩
១.២.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង........................................................ ៣១
១.២.៤ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ...................................... ៣២
១.២.៥ ការស្តាប់ចម្លើយ និងបទបញ្ជាឲ្យចូលខ្លួន..................................................៣២
**១.៣ ការឃាត់ខ្លួន**.......................................................................................... ៣៤
១.៣.១ លក្ខខណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់ខ្លួន ........................................ ៣៤
១.៣.២ រយៈពេលនៃការឃាត់ខ្លួន ...................................................................... ៣៤
១.៣.៣ ការឃាត់ខ្លួនចំពោះអនីតិជន ................................................................... ៣៥
១.៣.៤ កំណត់ហេតុស្តីពីការឃាត់ខ្លួន................................................................. ៣៦
១.៣.៥ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន .....................................................៣៧
១.៣.៦ ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន....................................................៣៧
១.៣.៧ បញ្ជីនៃការឃាត់ខ្លួន ............................................................................. ៣៨
១.៣.៨ កំណត់ហេត់សរុបនៃកាឃាត់ខ្លួន ............................................................. ៣៨
**១.៤ ការបញ្ជូនខ្លួន** ........................................................................................ ៣៩
១.៤.១ ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ................................................ ៣៩
១.៤.២ រយៈពេលនៃការបញ្ជូនខ្លួន..................................................................... ៣៩
**១.៥ វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង** .............................................៤០
១.៥.១ ចិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង .................................................៤០
១.៥.២ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា និងនិទ្ទេសដែលត្រូវចុះនៅក្នុង
កំណត់ហេតុ......................................................................................................៤០
១.៥.៣ ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍..............................................៤១
១.៥.៤ មោឃភាព នៃការមិនគោរពវិធានបញ្ញត្តិ.......................................................៤១
**កថាខណ្ឌទី២ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង**...............................៤២
**២.១ អត្ថន័យបទល្មើសមិនជាក់ស្តែង**...................................................................៤២
២.១.១ ការបើកការស៊ើបអង្កេតបឋម.................................................................. ៤៣
២.១.២ វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម............................................. ៤៣
២.១.៣ មោឃាភាពនៃការមិនគោរពវិធានបញ្ញាត្តិ....................................................៤៤
**២.២ ការឆែកឆេរ**.............................................................................................៤៤

២.៣ ការបញ្ជូនឲ្យចូលខ្លួន ......................................................................... ៤៥

២.៤ ការឃាត់ខ្លួនជនសង្ស័យ ......................................................................... ៤៦

២.៥ កំណត់ហេតុក្នុងការស្តាប់ចម្លើយ ......................................................................... ៤៦

**កថាខណ្ឌទី៣ ការបញ្ជប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌** ......................... ៤៦

**កថាខណ្ឌទី៤ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌** ......................... ៤៧


## ជំពូកទី៣

## ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ


**ផ្នែកទី១ បញ្ហាប្រឈម** ......................................................................... ៤៩

**កថាខណ្ឌទី១ ការធ្វេសប្រហែសគួបផ្សំ និងការខ្វះសម្ភារមធ្យោបាយ** ......................... ៤៩

១.១ ការងារមួយចំនួនអសកម្ម ......................................................................... ៤៩

១.២ ការចាត់តាំងអនុវត្ត ......................................................................... ៤៩

១.៣ ការស៊ើបអង្កេត និងការបង្ក្រាប ......................................................................... ៤៩

១.៤ ការខ្វះមធ្យោបាយ ......................................................................... ៤៩

**កថាខណ្ឌទី២ មន្ត្រីនគរបាលយុត្តិធម៌មានអាណាព្យាបាលពីរ** ......................... ៤៩

២.១ គោលការណ៍ច្បាប់ ......................................................................... ៥០

២.២ អនុវត្តជាក់ស្តែង ......................................................................... ៥០

**កថាខណ្ឌទី៣ សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ** ......................... ៥០

**ផ្នែកទី២ ដំណោះស្រាយ** ......................................................................... ៥១

**កថាខណ្ឌទី១ យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់** ......................... ៥១

**កថាខណ្ឌទី២ យន្តការពង្រឹងការអនុវត្តច្បាប់** ......................... ៥១

២.១ ការលុបបំបាត់អំពើពុករលួយ ......................................................................... ៥១

២.២ ការលុបបំបាត់វប្បធម៌អន្តរាគមន៍ ......................................................................... ៥២

២.៣ ការលុបបំបាត់វប្បធម៌និទណ្ឌភាព ......................................................................... ៥២

**សេចក្តីសន្និដ្ឋាន** ......................................................................... ៥៤

**អនុសាសន៍** ......................................................................... ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតណាស់អំពើដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើស ម្យ៉ាងវិញទៀតបទល្មើសព្រហ្មទណ្ឌ ជាអំពើទាំងឡាយណាដែលបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ហើយអំពើទាំងនោះ គឺជាការបំពានទៅនឹងច្បាប់ព្រហ្មទណ្ឌ។ បទល្មើសដែលមានការកើនឡើង ឬ ថយចុះ វាអាស្រ័យទៅនឹងជំនាញ ឬ សមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងបច្ចេកទេសនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ថាតើការប្រព្រឹត្តទៅស្របតាមវិជ្ជាជីវៈដែរ ឬ ទេ? ហើយវាស្របទៅនឹងអ្វីដែលមានចែងនៅក្នុងច្បាប់ដែរ ឬ ទេ? ជាក់ស្តែង ការស្វែងរកប្រមូលនូវភស្តុតាង ការសាកសួរ ការឃាត់ខ្លួន ការចាប់ខ្លួន ការបញ្ជូនខ្លួន គឺជាបច្ចេកទេសរបស់មន្ត្រីនគរបាលយុត្តិធម៌ ហើយមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីសម្រាប់ធ្វើការស៊ើបអង្កេត និងស្វែងរកបទល្មើស ព្រមទាំងបង្ការ និងបង្ក្រាបបទល្មើសនៅក្នុងសង្គមជាតិ។ ម្យ៉ាងវិញទៀត យុត្តិសាស្ត្រ ឬ បច្ចេកទេសរបស់មន្ត្រីនគរបាលនេះ គឺជាមូលដ្ឋានសម្រាប់ធ្វើការស្វែងរកនូវភាពយុត្តិធម៌ជូនសង្គម ព្រមទាំងជនរងគ្រោះឱ្យមានតម្លាភាព។

ដើម្បីឱ្យការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ មានប្រសិទ្ធភាព និងភាពជោគជ័យនោះ ត្រូវមានដំណោះស្រាយមួយចំនួន ហើយដំណោះស្រាយនោះ គឺវាមានការពាក់ព័ន្ធទៅនឹងសិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ជនជាសង្ស័យ សាក្សី ឬ ក៏ជនរងគ្រោះ។

នៅក្នុងប្រធានបទមួយនេះ គឺមានវិសាលភាពគ្របដណ្តប់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយដែលបានកើតឡើង រហូតដល់ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័ននគរបាលយុត្តិធម៌ ដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។ វាមានវិសាលភាពគ្រប់ដណ្តប់ទូទាំងប្រទេសកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៧ ដែលក្រមនីតិវិធីព្រហ្មទណ្ឌ បានចូលជាធរមានរហូតមកដល់បច្ចុប្បន្ន។

ការស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានអត្ថប្រយោជន៍សម្រាប់ប្រជាពរដ្ឋ និងសិស្សនិស្សិត ដែលមានបំណងចង់ធ្វើការស្វែងយល់នូវចំណេះដឹងទូទៅ នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ ជាពិសេស សម្រាប់អ្នកធ្វើការស្រាវជ្រាវ និងអ្នកសិក្សាផ្នែកនីតិសាស្ត្រផងដែរ។

ដោយហេតុថាសារណារបស់ក្រុមយើងខ្ញុំនេះលើកយកតែក្នុងដំណាក់កាល ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ អាស្រ័យនេះហើយក្រុមរបស់យើងខ្ញុំ ព្យាយាមពន្យល់លម្អិតអំពី ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ក្នុងដំណាក់កាលមន្ត្រី

នគរបាលយុត្តិធម៌។ នៅក្នុងខ្លឹមសារនៃប្រធានបទមួយនេះ ត្រូវបានចែកចេញជា **៣ ជំពូក** ដែលនៅក្នុង **ជំពូកទី១** និយាយអំពី **សមាសសភាពរបស់នគរបាលយុត្តិធម៌** ហើយក៏បានចែកចេញ ជា២ផ្នែកទៀត គឺ**ផ្នែកទី១** មន្ត្រីនគរបាលយុត្តិធម៌ និង**ផ្នែកទី២** មន្ត្រីរាជការ **និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួនចំណែកឯ** **ជំពូកទី២** វិញបកស្រាយអំពី **ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌** ដែលបានធ្វើការបែងចែកជា **១ផ្នែក** គឺ **ផ្នែកទី១ សិទ្ធិអំណាចនៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាង** ចំពោះ **ជំពូកទី៣** វិញពណ៌នាអំពី **ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ** ដោយបានចែកចេញជា **២ផ្នែក** ផងដែរ គឺ**ផ្នែកទី១ បញ្ហាប្រឈម** និង**ផ្នែកទី២ ដំណោះស្រាយ** ដែលក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយទៅតាមចំណុចនីមួយៗទៅតាមការកំណត់ខាងលើ។

# ជំពូកទី១

# សមាសភាពរបស់នគរបាលយុត្តិធម៌

# ជំពូកទី១

## សមាសភាពរបស់នគរបាលយុត្តិធម៌

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៥៧ បានបញ្ញត្តិថា នគរបាលយុត្តិធម៌មាន ០៣ (បី) ប្រភេទគឺ ទី១ **មន្ត្រីនគរបាលយុត្តិធម៌** ទី២ **ភ្នាក់ងារនគរបាលយុត្តិធម៌** និងទី៣ **មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។** តើពាក្យថា នគរបាលយុត្តិធម៌មានន័យដូចម្តេច? ដោយផ្អែកលើមាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ មានន័យថាជាជំនួយឱ្យស្ថាប័នអយ្យការ (ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ) នៅក្នុងការត្រួតពិនិត្យបទល្មើសទាំង បទលហុ បទមជ្ឈិម និង បទឧក្រិដ្ឋ នៅក្នុងគោលបំណងស្វែងរកឱ្យឃើញនូវធាតុផ្សំទាំង០៣ (បី) មានដូចខាងក្រោម ៖

| ល.រ | ចំណុចគោល | ខ្លឹមសារលម្អិត |
|---|---|---|
| ១ | ធាតុនីត្យានុកូល | មានចែងជាធរមានក្នុងក្រមនីតិព្រហ្មទណ្ឌ (មានបទល្មើស លុះត្រាតែមានច្បាប់ធរមានជាមុន) |
| ២ | ធាតុសត្យានុម័ត | • មានអំពើ (សកម្មនិងអកម្ម)<br>• ព្យសនកម្ម (សម្ភារៈ ផ្លូវកាយ ផ្លូវចិត្ត)<br>• ទំនាក់ទំនងផ្ទាល់រវាងអំពើ និងព្យសនកម្ម ដែលពាក់ព័ន្ធទៅនឹងបទល្មើស<br>• ភស្តុតាង គឺសំដៅលើស្លាកស្នាម<br>• វត្ថុតាង គឺសំដៅលើឧបករណ៍ដែលធ្វើឱ្យមានរបួសស្នាមទៅជនរងគ្រោះ<br>• ពេលវេលា និងទីកន្លែង |
| ៣ | ធាតុអត្តនោម័ត | • ចេតនាទុច្ចរិត ដែលកើតចេញពីឆន្ទៈ ហេតុផល និងគោលបំណង<br>• អចេតនា ដែលកើតចេញពីការធ្វេសប្រហែស ខ្ជីខ្ជារ និងមិនប្រុងប្រយ័ត្ន |

| | | |
|---|---|---|
| | | • សម្គាល់ជននោះមិនវិកលចរិក មិនសរសៃប្រសាទ និងមិនមែនជាអនីតិជន (អាយុក្រោម ១៨ឆ្នាំ) |

បន្ទាប់មកការកសាងសំណុំរឿងរួចបញ្ជូនទៅស្ថាប័នតុលាការ ដើម្បីចាត់ការតាមនីតិវិធីបន្តទៀត។ ក្រោយពីបានយល់ច្បាស់ពីនិយមន័យ នៃនគរបាលយុត្តិធម៌រួចមក យើងនឹងធ្វើការសិក្សាឱ្យបានលម្អិតអំពីសមាសភាពនីមួយៗ របស់នគរបាលយុត្តិធម៌ដូចតទៅ៖

## ផ្នែកទី១ មន្ត្រីនគរបាលយុត្តិធម៌

គឺសំដៅលើមន្ត្រីមាននីតិសម្បទាពេញលេញដែលទទួលបានតាមរយៈ ការប្រឡងប្រជែងនូវវគ្គសិក្សាមន្ត្រីនគរបាលយុត្តិធម៌ នៅសាលាកងរាជអាវុធហត្ថកំបូល ឬ សាលារាជបណ្ឌិតសភាវិជ្ជាជីវៈនគរបាលជាតិតាមរយៈឋានន្តរស័ក្តិ និងមុខងាររបស់អភិបាល និងអភិបាលរង មេឃុំ និងចៅសង្កាត់ ប្រធាន និងអនុប្រធាននាយកដ្ឋាន ការិយាល័យ ផ្នែក ប៉ុស្តិ៍ និងអង្គភាពផ្សេងទៀត ស្នងការ និងស្នងការរងនគរបាល អធិការ និងអធិការរងនគរបាល មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ និងការទទួលបានដោយស្វ័យប្រវត្តិសម្រាប់នាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ។ បន្ទាប់មកទៀតយើងត្រូវដឹងថា តើបុគ្គលណាដែលមានសិទ្ធអំណាចក្នុងការតែងតាំង និងចេញសេចក្តីសម្រេចជាមន្ត្រីនគរបាលយុត្តិធម៌? ហើយទីតាំងស្បថដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ពេញលេញនោះនៅឯណា? តើនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានប្រព្រឹត្តិកំហុសឆ្គងនៅពេលបំពេញមុខងារ ឬ បេសកកម្មផ្សេង តើនឹងមានចំណាត់ការយ៉ាងដូចម្តេចចំពោះពួកគាត់។ដើម្បីធ្វើការឆ្លើយតបឱ្យយល់កាន់តែច្បាស់ នូវចម្ងល់ក៏ដូចជាសំនួរមួយចំនួនដែលបានចោទសួរខាងលើរនេះ គប្បីយើងត្រូវសិក្សាស្វែងយល់ដូចតទៅ៖

### កថាខណ្ឌទី១ ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

យើងសុំធ្វើការបែងចែកចេញជា ០៣ (បី) ប្រភេទទាក់ទិនទៅនឹងការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ទី១ **ការទទួលបានតាមរយៈការប្រឡងប្រជែង** ទី២ **ការទទួល បានតាមរយៈ ឋានន្តរស័ក្តិ និងមុខងារ** និងទី៣ **ការទទួលបានដោយស្វ័យប្រវត្តិ**។

#### ១.១ ការទទួលបានតាមរយៈការប្រឡងប្រជែង

ការប្រឡងប្រជែងនេះ គឺតម្រូវឱ្យនគរបាលយុត្តិធម៌ចាំបាច់ត្រូវឆ្លងកាត់ការសិក្សា និងការប្រឡងយកសញ្ញាបត្រមន្ត្រីជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយទើបអាចក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមាននីតិសម្បទាពេញលេញបាន។ ដើម្បីមានសិទ្ធិគ្រប់គ្រាន់នៅក្នុងការប្រឡងយកសញ្ញាបត្រមន្ត្រីជាន់ខ្ពស់ ខាងនគរបាលយុត្តិធម៌បាន គឺត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនដែលបានចែងក្នុងមាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូចតទៅ៖

### ១.១.១ លក្ខខណ្ឌដើម្បីប្រឡងយកសញ្ញាបត្រជាន់ខ្ពស់បស់នគរបាលយុត្តិធម៌

យោងតាមមាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[1] គឺមានតែមន្ត្រីនគរបាលជាតិ និងនាយទាហានកងរាជអាវុធហត្ថតែប៉ុណ្ណោះ ដែលមានសិទ្ធិប្រឡងយកសញ្ញាបត្រជាន់ខ្ពស់របស់នគរបាលយុត្តិធមិបាន។

**ក. មន្ត្រីនគរបាលជាតិ**

មន្ត្រីនគរបាលជាតិ គឺសំដៅទៅលើមន្ត្រីដែលមានឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ត្រី (ស័ក្តិ១) ឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុតរយ:ពេល០២ (ពីរ) ឆ្នាំក្នុងនគរបាលជាតិរួចហើយ។ នៅពេលដែលគាត់ត្រូវបានមេអង្គភាពសាមីខ្លួន ទទួលស្គាល់ថាមន្ត្រីនោះគាត់មានលក្ខខណ្ឌគ្រប់គ្រាន់ដូចទៅតាមនូវអ្វីដែលច្បាប់បានកំណត់ក្នុងមាត្រា៦០ នៃក្រមនេះ រួចហើយគាត់ត្រូវទៅដាក់ពាក្យស្នើសុំចូលរៀនវគ្គ មន្ត្រីនគរបាលយុត្តិធមិនៅសាលារាជបណ្ឌិតសភាវិជ្ជាជីវ:នគរបាលជាតិ។ ពុំមានការប្រឡងផ្ទៃក្នុងអ្វីឡើយ ព្រោះនៅពេលដែលសាលារាជបណ្ឌិតសភាវិជ្ជាជីវ:នគរបាលជាតិជ្រើសរើសសិក្ខាកាម នឹងជូនដំណឹងនេះទៅដល់ការិយល័យបុគ្គលិកដើម្បីចាត់តាំង មន្ត្រីនគរបាលជាតិទៅ សិក្សារៀនសូត្ររយ:ពេល ០២ ឆ្នាំ។

**ខ. នាយទាហាន នៃកងរាជអាវុធហត្ថ**

នាយទាហាននៃកងរាជអាវុធហត្ថ គឺបានសំដៅទៅលើ នាយទាហានដែលមានឋានន្តរស័ក្តិចាប់ពីនាយទាហាន ឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុតរយ:ពេល ០២ (ពីរ) ឆ្នាំក្នុងកងរាជអាវុធហត្ថរួចហើយ។ ត្រង់ចំណុចនេះគឺសំដៅទៅដល់មន្ត្រីកងរាជអាវុធហត្ថ ទាំងអស់មិនថាមានតួនាទី មុខងារនៅក្នុងស្នងការ មន្ទីរ ឬ ការិយាល័យអ្វីឡើយឱ្យតែមេអង្គភាពទទួលស្គាល់ថាមន្ត្រីនោះ មានលក្ខខណ្ឌដូចនូវអ្វីដែលច្បាប់បានកំណត់ក្នុងមាត្រា៦០ នៃក្រមនេះ (ព្រោះពួកគាត់ជាមន្ត្រីអនុវត្តច្បាប់) ដូច្នេះ គឺពួកគាត់អាចដាក់ពាក្យស្នើសុំចូលរៀន វគ្គមន្ត្រីនគរបាលយុត្តិធមិនៅសាលាកងរាជអាវុធហត្ថកំបូលបាន ដោយធ្វើការប្រឡងប្រជែងផ្ទៃក្នុងរបស់អង្គភាព ជាមុនសិនព្រោះចំនួនសិក្ខាកាមទៅសិក្សាមានកំណត់។ ក្រោយពីបានប្រឡងផ្ទៃក្នុងជាប់ ការិយាល័យបុគ្គលិកត្រូវរៀបចំបញ្ជូនឈ្មោះនាយទាហានដែលមានចំនួនកំណត់ទៅសិក្សារៀនសូត្ររយ:ពេល ០៦ ខែ។ **(ជាក់ស្តែងសព្វថ្ងៃនេះ ការសិក្សាវគ្គមន្ត្រីនគរបាលយុត្តិធមិ ជាទូទៅគឺមាន តែមន្ត្រីនៅក្នុងស្នងការនគរបាលយុត្តិធមិ នៃកងរាជអាវុធហត្ថ តែប៉ុណ្ណោះដែលមានអត្ថិភាពបានទៅសិក្សាវគ្គមន្ត្រីនគរ**

1. យោងតាម អនុសាសន៍របស់ ឯកឧត្តម ប៊ិន ហុន អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធមិនៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧

**បាលយុត្តិធម៌នេះ**)[2]។

**ចំណាំ** មន្ត្រីនគរបាលជាតិ និងនាយទាហាន នៃកងរាជអាវុធហត្ថនឹងត្រូវទទួលបានសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌បន្ទាប់ពីពួកគាត់បានប្រឡងជាប់រួចហើយ គាត់នឹងក្លាយខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌។

### ១.១.២ បែបបទនៃការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

បែបបទនៃការប្រឡងដើម្បី យកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ គឺសំដៅទៅលើសមត្ថភាពរបស់មន្ត្រីនគរបាលជាតិ និងនាយទាហានកងរាជអាវុធហត្ថផ្ទាល់តែម្តងដើម្បីប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។ ហើយនៅក្នុងការប្រឡងនេះគឺមានវិញ្ញាសាប្រឡងប្រភេទណាខ្លះ? ហើយនឹងមានសមាសភាពគណៈមេប្រយោគមកពីស្ថាប័នជំនាញណាខ្លះ?

#### ក. វិញ្ញាសាប្រឡង

ពាក់ព័ន្ធនឹងវិញ្ញាសាប្រឡងបែបវិជ្ជាជីវៈជាមន្ត្រីនគរបាលយុត្តិធម៌ ជាទូទៅមានចំនួន០៣ (បី) មុខវិជ្ជា យោងទៅតាមច្បាប់បានកំណត់នៅក្នុងមាត្រា៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានដូចជា ៖ ទី១ **វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ** ទី២ **វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ** និងទី៣ វិញ្ញាសាស្តីពី **ករណីកិច្ចសាស្ត្រ** ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងដោយអង្គការសហប្រជាជាតិ[3]។

#### ខ. គណៈមេប្រយោគ

គណៈមេប្រយោគនៃការប្រឡងប្រជែងនោះ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬ ចៅក្រមអយ្យការអមតុលាការកំពូល ដែលទទួលមុខងារនេះ[4]។ ហើយសមាសភាពនៃគណៈមេប្រយោគដែលទាក់ទិនទៅនឹងមន្ត្រីនគរបាលជាតិ ឬ យោធិននៃកងរាជអាវុធហត្ថ មានដូចតទៅ ៖

- ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល
- ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ (សម្រាប់យោធិននៃកងរាជអាវុធហត្ថ) ឬ តំណាង ២ (ពីរ) រូប មកពីក្រសួងមហាផ្ទៃ (សម្រាប់មន្ត្រីនគរបាលជាតិ) ទាំងនេះគឺ អាស្រ័យទៅតាមការប្រឡងរបស់ខាងមន្ត្រីនគរបាលជាតិ ឬ ក៏ខាងយោធិននៃកងរាជអាវុធហត្ថ។

2.. យោងតាម ប្រសាសន៍របស់លោក ឧត្តមសេនីយត្រី លី សាត់សាយ ជាមេបញ្ជាការរង អ.ហ.ភ.ព ឆ្នាំ២០១៦
3. មាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
4. មាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

**ចំណាំ** នៅពេលដែលគាត់ប្រឡងជាប់ទទួលបានសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយ សញ្ញាបត្រ[5] នេះត្រូវចុះហត្ថលេខានឹងមានបោះត្រារួម ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ មានន័យថាបើជាមន្ត្រីនគរបាលយុត្តិធម៌ដែលចេញមកពីខាងកងរាជអាវុធហត្ថ គឺមានហត្ថលេខាហើយបោះត្រាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ តែបើចំពោះមន្ត្រីនគរបាលយុត្តិធម៌ដែលចេញមកពីខាងនគរបាលជាតិ គឺត្រូវមានហត្ថលេខា និងមានបោះត្រាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ១.២ ការទទួលបានតាមរយៈឋានន្តរស័ក្តិ និងមុខងារ

ដោយយល់ឃើញថានៅក្នុងមាត្រា៦០ វាក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងនូវចំណុចជាច្រើនដែលពាក់ព័ន្ធទៅនឹងការទទួលបាន នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈឋានន្តរស័ក្តិ និងមុខងារ។ ដូច្នេះដើម្បីងាយយល់យើងខ្ញុំសូមធ្វើការបែងចែកជា ៦ ចំណុចផ្សេងៗ គ្នាដូចខាងក្រោម ៖

#### ១.២.១ អភិបាល និងអភិបាលរង

នៅក្នុងចំណុច "**ក**" នៃក្រមនេះ មានដូចជា អភិបាល និងអភិបាលរងខេត្ត រាជធានី អភិបាល និងអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលមុខងាររបស់ពួកគាត់ គឺកើតឡើងពីការតែងតាំង តាម (មាត្រា ១៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨)។

#### ១.២.២ មេឃុំ និងចៅសង្កាត់

នៅក្នុងចំណុច "**ក**" នៃមាត្រានេះដដែលក៏ចែងពី មេឃុំ និងចៅសង្កាត់ដែរ ដែលមុខងាររបស់ពួកគាត់គឺកើតឡើងពីការបោះឆ្នោតជាសកល។

#### ១.២.៣ ប្រធាន និងអនុប្រធាននាយកដ្ឋាន ការិយាល័យ ផ្នែកប៉ុស្តិ៍ និងអង្គភាពផ្សេងទៀត

នៅក្នុងចំណុច **ខ គ ឃ ច ឆ ជ ឈ ឌ ឍ** នៃ មាត្រានេះសំដៅលើ ៖

- ចំណុច "**ខ**" គឺប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខហើយ ប្រធាន និងអនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។
- ចំណុច "**គ**" គឺជា ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌនឹង

5. សញ្ញាបត្រជាន់ខ្ពស់ខាងមន្ត្រីនគរបាលយុត្តិធម៌ (នៃកងរាជអាវុធហត្ថ)

ស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

- ចំណុច "**ឃ**" គឺជាប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ៖
  . នាយកដ្ឋាននគរបាលព្រំដែន(ចំពោះបទល្មើសឆ្លងដែន)
  . នាយកដ្ឋាននគរបាលទេសចរណ៍
  . មន្ទីរប្រឆាំងគ្រឿងញៀន
  . ស្នងការពិសេសការពារបេតិកភណ្ឌ។
- ចំណុច "**ច**" គឺប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះ ស្នងការនគរបាលខេត្ត រាជធានី មាន៖
  . ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល
  . ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
  . ការិយាល័យនគរបាលសេដ្ឋកិច្ច
  . ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
  . ការិយាល័យប្រឆាំងគ្រឿងញៀន
  . ការិយាល័យប្រឆាំងភេរវកម្ម
  . ការិយាល័យជនបរទេស។
- ចំណុច "**ឆ**" គឺប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ។
- ចំណុច "ជ" គឺប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែក នគរបាលចរាចរ (ចំពោះបទល្មើសចរាចរ)។ ប្រធាន និងអនុប្រធានការវិយាល័យ គ្រប់គ្រងជាតិផ្ទះ។ ប្រធាន និងអនុប្រធានអង្គភាព និងអនុប្រធាន ការវិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការវិយាល័យនគរបាលទេសចរណ៍។
- ចំណុច "**ឈ**" គឺជាប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ (ចំពោះបទល្មើសព្រហ្មទណ្ឌ)

- ចំណុច "ឌ" គឺប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក នៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។
- ចំណុច "ឍ" គឺប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀតដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបង្កើតឡើងក្នុងករណីចាំបាច់។

**១.២.៤ ស្នងការ និងស្នងការរងនគរបាល**

នៅក្នុងចំណុច "ង" នៃមាត្រានេះ សំដៅលើស្នងការ និងស្នងការរងនគរបាលខេត្ត រាជធានី។

**១.២.៥ អធិការ និងអធិការរងនគរបាល**

នៅក្នុង ចំណុច "ឆ" នៃមាត្រានេះដែរ សំដៅទៅលើស្នងការ និងស្នងការរងនគរបាលក្រុង ស្រុកខណ្ឌ។

**១.២.៦ មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ**

នៅចំណុច "**ញ ដ ឋ**" នៃមាត្រានេះមាន៖

ចំណុច "ញ" គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ប្រចាំក្រសួងការពារជាតិ។

ចំណុច "ដ" គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌប្រចាំ ខេត្ត រាជធានី។

ចំណុច "ឋ" គឺសំដៅលើមេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌប្រចាំ ក្រុង ស្រុក ខណ្ឌ[6]។

**១.៣ ការទទួលបានដោយស្វ័យប្រវត្តិ**

តើមានន័យយ៉ាងដូចម្តេច ចំពោះការទទួលបានដោយស្វ័យប្រវត្តិនូវគុណសម្បត្តិ ជាមន្ត្រីនគរបាលយុត្តិធម៌? ក្នុងនោះដែលបើយោងតាមបញ្ញត្តិក្នុងមាត្រា៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មានន័យថា មន្ត្រីទាំងឡាយណាដែលបានបំពេញនូវ លក្ខខណ្ឌមុននឹងក្រមនេះចូលជាធរមាននោះនឹងមានការផ្តល់ នូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។ ដូច្នេះដើម្បីឱ្យងាយយល់យើងខ្ញុំសុំលើកយកមន្ត្រីទាំង ០២ (ពីរ) ប្រភេទមកសិក្សាដូចខាងក្រោម៖

**១.៣.១ សម្រាប់នាយទាហាន នៃកងរាជអាវុធហត្ថ**

គឺសំដៅទៅរកនាយទាហាន នៃកងរាជអាវុធហត្ថដែលមានវិញ្ញាបនបត្របញ្ជាក់ ការសិក្សា

6. ដោយសារតែមានការកែប្រែការគ្រប់គ្រងរដ្ឋបាលដែនដី ទើបយើងធ្វើការកែប្រែ ពាក្យពេចន៍ឱ្យស្របទៅតាមបរិបទថ្មីនៃ រដ្ឋធម្មនុញ្ញដែលបានប្រកាសឱ្យប្រើនូវថ្ងៃទី ២៤ កញ្ញា ១៩៩៣ ហើយត្រូវបានធ្វើវិសោធនកម្មថ្មីត្រង់មាត្រា១៤៥ និង១៤៦ថ្មី (មួយ) និងស្របទៅតាមបរិបទថ្មីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨(ក្នុងឧបសម្ព័ន្ធ)

ស្តីពីមន្ត្រីប៉ូលីសតុលាការ មុនពេលក្រមនីតិវិធីនេះចូលជាធរមានត្រូវទទួលបានដោយ ស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌។

**១.៣.២ សម្រាប់នាយនគរបាលជាតិ**

សម្រាប់នាយនគរបាលជាតិ គឺសំដៅទៅលើ នាយនគរបាលជាតិដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្ដីអំពី មន្ត្រីនគរបាលយុត្តិធម៌ដែលចេញដោយសាលាភូមិន្ទនគរបាល មុនពេលក្រមនីតិវិធីនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌[7]។

## កថាខណ្ឌទី២ ការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌រួចហើយ ពួកគាត់ត្រូវទទួលបាននូវការតែងតាំងជាមុនសិន។ ដូច្នេះហើយទើបធ្វើឱ្យបងប្អូន និងនិស្សិតមួយចំនួនបានចោទជាសំណួរថា តើបុគ្គលប្រភេទណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងមន្ត្រីនគរបាលយុត្តិធម៌? និងមានសេចក្តីសម្រេចប្រភេទណាដែរ នៅក្នុងការតែងតាំងមន្ត្រីនគរបាលយុត្តិធម៌? ដើម្បីឆ្លើយតបទាក់ទិនទៅនឹងសំណួរខាងលើនេះ យើងខ្ញុំសុំធ្វើការរៀបរាប់ដូចតទៅ ៖

**២.១ បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌**

បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌បាន គឺមានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ។ ដោយយោងតាមមាត្រា៦០ នៃក្រមនេះនៅត្រង់វាក្យខណ្ឌចុងក្រោយបង្អស់បានចែងថា រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរនបាល ឬ ជាអាណា-ព្យាបាល នៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយដែលមានចែងនៅក្នុងចំណុច ទី១ ទី២ និង ទី៣ នៃក្រមនេះ មានភារៈកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយណា ដែលត្រូវបំពេញមុខងារជា មន្ត្រីនគរបាលយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**២.២ សេចក្តីសម្រេចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌**

សេចក្តីសម្រេចក្នុងការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ គឺតម្រូវចេញប្រកាសរួមមួយរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយនឹងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធមានន័យថាបើជាមន្ត្រីនគរបាលយុត្តិធម៌ដែលចេញមកពីខាងនគរបាលជាតិ គឺត្រូវតែងតាំងដោយ "ប្រកាសរួម" រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តែបើសិនជាមកពីខាងកងរាជអាវុធហត្ថ គឺត្រូវតែងតាំង ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីការពារជាតិ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[8]។

---

7. វិញ្ញាបនបត្រ នេះមានគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធ
8. មាត្រា៦០ និង ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ សីហា ២០០៧

### កថាខណ្ឌទី៣ សម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីនាយទាហាននៃកងរាជអាវុធហត្ថ និងមន្ត្រីនគរបាលជាតិទទួលបាននូវការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ពី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាមីដោយបានចេញសេចក្តីប្រកាសរួមរួចហើយនោះ ក៏ពុំទាន់អាចទៅបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានភ្លាមនោះទេ គឺពួកគាត់ត្រូវតែឆ្លងកាត់នូវដំណាក់កាលមួយផ្សេងទៀត គឺការធ្វើសម្បថហើយក្នុងនោះផងដែរ យើងខ្ញុំបានញែកចេញជា ២ (ពីរ) ចំណុច ដើម្បីឱ្យងាយយល់ក្នុងការធ្វើសម្បថនេះ។

#### ៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

ទីកន្លែងដែលត្រូវធ្វើសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវធ្វើសម្បថនៅមុខសាលាឧទ្ធរណ៍។ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវតែស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន។ រីឯរូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[១]។

#### ៣.២ អញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីនគរបាលយុត្តិធម៌

យោងតាមមាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានករណីលើកលែងចំពោះសម្បថ១ ព្រោះបានកំណត់ថា (សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយនៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយ)។

### កថាខណ្ឌទី៤ កំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងពេលអនុវត្តមុខងារ

ក្រោយពេលដែលទទួលបានការតែងតាំង ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ហើយក្រោយពីបានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍រួចមក មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិអំណាចស្របច្បាប់នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដូចដែលបានផ្តល់ឱ្យដោយ ក្រមនីតិ-វិធីព្រហ្មទណ្ឌ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ បានប្រព្រឹត្តនូវកំហុសខុសឆ្គងក្នុងពេលអនុវត្តមុខងាររបស់ខ្លួន តើមានទណ្ឌកម្មយ៉ាងដូចម្តេចខ្លះ? ហើយដើម្បីដាក់ទណ្ឌកម្មបានតើគេត្រូវមាន នីតិវិធីខាងវិន័យបែបណាខ្លះ? សំណួរទាំងនេះនឹងត្រូវបកស្រាយជូន ដូចតទៅ ៖

#### ៤.១ នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយណា ដែលប្រព្រឹត្តិដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួនត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ទៅដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើមដំណើការនីតិវិធីវិន័យ។ បន្ទាប់មក អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការ

---

១. មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ សីហា ២០០៧

ជាបន្តនៃនីតិវិធីវិន័យនេះ[10]។

### ៤.២ ទណ្ឌកម្មចំពោះមន្ត្រីនគរបាលយុត្តិធម៌

ចំពោះទណ្ឌកម្មទៅលើមន្ត្រីនគរបាលយុត្តិធម៌ នៅពេលប្រព្រឹត្តិកំហុសក្នុងពេលអនុវត្តមុខងារ។ យើងខ្ញុំសូមធ្វើការបែងចែកជា ០២ (ពីរ) ចំណុចគឺ ទីមួយ ទណ្ឌកម្មខាងវិន័យ និងទីពីរ ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌។

#### ក. ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យទាំងឡាយណារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។ កាលណាមន្ត្រីនគរបាលយុត្តិធម៌ ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួនយុត្តាធិការស៊ើបសួរ ឬ ជំនុំជម្រះដែលទទួលបន្ទុកក្នុងរឿងនេះត្រូវផ្ទេរសំណុំរឿងតាមសេចក្តីសម្រេច តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមីពាក្យសុំដកសិទ្ធិនេះត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា[11]។

#### ខ. ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់មានវិសមិតភាព ជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម៖

ទី១ ហាមឃាត់មិនឱ្យបំពេញមុខងារ ជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើនបំផុត។

ទី២ ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវកោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រានូវសេចក្តីសង្កេតរបស់មន្ត្រីនោះទុក។ ចំណែកសាមីជនអាចរកជំនួយពីមេធាវី ឬ ពីទីប្រឹក្សាណាម្នាក់តាមការជ្រើសរើសរបស់ខ្លួន។ ចំពោះសេចក្តីសម្រេចពីការហាមឃាត់ត្រូវតែបញ្ជាក់សំអាងហេតុ និងត្រូវផ្តល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីនៃក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ។ សេចក្តីសម្រេចនេះអាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬ បន្ថយរយៈពេល

10. មាត្រា៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
11. មាត្រា៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសី

នៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចការហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុបានតែក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃតែប៉ុណ្ណោះ គិតចាប់ពីថ្ងៃ ទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យបណ្តឹង។ សេចក្តីសម្រេចនេះមិនអាចប្តឹងតវ៉ាបានឡើយ។ ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានឡើយ។ ហើយមន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់នោះ ឬ បន្ថយរយៈពេលនៃការហាមឃាត់នោះ។ កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញដោយបំពាន លើសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នេះត្រូវចាត់ទុកជាមោឃៈ[12]។

## ផ្នែកទី២ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេស សម្រាប់ពិនិត្យបទល្មើសមួយចំនួន

នៅក្នុងផ្នែកនេះ ខ្ញុំនឹងបញ្ជាក់ជូនថាតើមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះជានរណាគេ? តើមានច្បាប់ណាខ្លះដែលបានផ្តល់នីតិសម្បទាពិសេសដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ? ហើយការតែងតាំងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះត្រូវគោរពនូវបែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាអ្វីខ្លះ? បន្ទាប់ពីការតែងតាំងរួចហើយ តើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះត្រូវទៅស្បថនៅឯណា ? ចុះនៅពេលដែលមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះបានប្រព្រឹត្តកំហុសក្នុងពេលបំពេញមុខងារ តើនឹងមានចំណាត់ការបែបណាខ្លះចំពោះពួកគាត់? ដើម្បីយល់កាន់ច្បាស់នូវសំណួរទាំងនេះទាមទារឱ្យយើងធ្វើ ការសិក្សានូវចំណុចលម្អិតមួយចំនួនដូចខាងក្រោម៖

### កថាខណ្ឌទី១ ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន

ដោយមូលហេតុថា ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមានចំនួនច្រើនប៉ុន្តែ ប្រធានបទយើងខ្ញុំ ពុំបានផ្តោតសំខាន់ទៅលើចំណុចនេះ ខ្លាំងពេកទេអាស្រ័យហេតុនេះដើម្បី

12. មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ផ្តល់ជាជំនួយក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងចំនុចនេះ ខ្ញុំសូមលើកយកមក បង្ហាញតែច្បាប់ចំនួន០២ (ពីរ) តែប៉ុណ្ណោះ ទី១. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងទី២ ច្បាប់ស្តីពីព្រៃឈើ។ ច្បាប់ទាំង០២ ប្រភេទនេះយើងខ្ញុំនឹងធ្វើការបង្ហាញ ជូនដូចតទៅៈ

### ១.១ តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

យោងតាមមាត្រា១០ នៃច្បាប់នេះ[13] មន្ត្រីនៃក្រសួងកិច្ចការនារី បំរើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់ខាងលើត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជូសមុខឱ្យជនរងគ្រោះក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

### ១.២ តាមរយៈច្បាប់ស្តីពីព្រៃឈើ

យោងតាមមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់នេះ[14] មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺសំដៅទៅលើមន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ មានន័យថាត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ មន្ត្រីរដ្ឋបាលព្រៃឈើ ធ្វើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទា។

## កថាខណ្ឌទី២ ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

បន្ទាប់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃផ្សេងទៀតនោះ ទទួលបាននូវនីតិវិធីសម្បទាពិសេស រួចហើយពួកគេត្រូវទទួលបាននូវការតែងតាំងជាមុនសិន។ អាស្រ័យហេតុនេះទើបមានសំណួរចោទសួរថា តើបុគ្គលប្រភេទណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងពួកគាត់? តើមានសេចក្តីសម្រេចប្រភេទណាដែរ ក្នុងការតែងតាំងពួកគាត់? ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះបានយើងត្រូវសិក្សាដូចតទៅ ៖

### ២.១ បុគ្គលដែលមានសិទ្ធិអំណាចក្នុងការតែងតាំង

គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ព្រោះបើផ្អែកលើមាត្រា៨២ នៃក្រមនេះ[15] ត្រង់វាក្យខណ្ឌ២ បានចែងថា "បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់រវាង

13.ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ តុលា ២០០៥ (មានក្នុងឧបសម្ព័ន្ធ)

14. ច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧ (មានក្នុងឧបសម្ព័ន្ធ)

15. មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ"។ **<u>ឧទាហរណ៍</u>** បើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្នុងក្រសួងកិច្ចការនារី ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី។ ចំណែកមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូច្នេះពួកគាត់ត្រូវមានការ តែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ២.២ សេចក្តីសម្រេចក្នុងការតែងតាំង

ដូចដែលបានដឹងស្រាប់ហើយថា រដ្ឋមន្ត្រីមានសិទ្ធិចេញ "ប្រកាស" ដើម្បីតែងតាំងមន្ត្រីមួយចំនួនដែលនៅក្រោមឱវាទរបស់ខ្លួន តែបើរដ្ឋមន្ត្រីនៃក្រសួងពីរផ្សេងៗគ្នាសម្រេចតែងតាំងមន្ត្រី តែមួយដូចគ្នា ដូច្នេះសេចក្តីម្រេចរួមគ្នានោះគេហៅថា ប្រកាសរួម ជាក់ស្តែងដើម្បីទទួលនីតិសម្បទា ជូនមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ត្រូវចេញ ប្រកាសរួមមួយ ដើម្បីទុកជាសេចក្តីសម្រេចក្នុងការ តែងតាំងពួកគាត់។ ឧទាហរណ៍: ចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកិច្ចការនារី ដូច្នេះ ពួកគាត់ត្រូវតែងតាំងដោយ ប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី។ រីឯមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដូច្នេះពួក គាត់ត្រូវតែងតាំងដោយ "ប្រកាសរួម" ផងដែរ រវាង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ[16]។

## កថាខណ្ឌទី៣ សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ បានចេញប្រកាសរួមតែងតាំងខ្លួនរួចហើយ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ មិនទាន់អាចទៅបំពេញមុខងារនេះបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងកាត់ដំណាក់កាលមួយផ្សេងទៀត ដូចមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ដែលដំណាក់កាលនេះគេឱ្យឈ្មោះថា ការធ្វើសម្បថ។

### ៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថ

យោងតាមមាត្រា៨២ ត្រង់វាក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតអាចមកបំពេញមុខងារបានទាល់តែឆ្លងកាត់នូវសម្បថជាមុនសិន។ ប៉ុន្តែសម្បថរបស់គាត់ មិនធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ ដូចមន្ត្រីនគរបាលយុត្តិធម៌នោះទេគឺគាត់ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ច តាមខេត្ត រាជធានី នីមួយៗ ដូចគ្នា

16. មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

នឹងភ្នាក់ងារ នគរបាលយុត្តិធម៌ដែរ។ រូបមន្តនៃសម្បថ[17] ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ៣.២ នត្ថិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នត្ថិភាពនៃអញ្ញត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺមានភាពខុសគ្នាពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ព្រោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺនត្ថិភាព[18] ចំពោះអញ្ញត្រកម្ម មានន័យថា បើយោងតាមមាត្រាខាង គឺមិនមានកំណត់នូវករណីលើកលែងចំពោះសម្បថឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិរួចរាល់នោះ។ ចំណុចនេះហើយដែលខ្ញុំមើលឃើញថាខុសគ្នាមន្ត្រីនគរបាលយុត្តិធម៌ក៏ដូចជាភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ព្រោះពួកគេមានករណីលើកលែងមួយចំពោះសម្បថរបស់ខ្លួនដូចបានរៀប រាប់ខាងដើមហើយថា "សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយនៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬ នៅពេលដែលទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលក្រោយទៀត"។ ផ្ទុយទៅវិញចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតទាំងនេះពុំមានចែងច្បាស់លាស់អំពីចំណុចនេះឡើយ។

## កថាខណ្ឌទី៤ កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលអនុវត្តមុខងារ

ក្រោយពេលទទួលបាននូវប្រកាសរួមតែងតាំងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងក្រោយពីបានទៅធ្វើសម្បថនៅចំពោះមុខសាលាដំបូងរួចមក មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ចំពោះការពិនិត្យលើបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍។ របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ។ ប្រសិនបើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតប្រព្រឹត្តកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួន តើនឹងមានទណ្ឌកម្មដូចម្តេចចំពោះពួកគាត់? ហើយដើម្បីដាក់ទណ្ឌកម្មបាន តើគេត្រូវមាននីតិវិធីខាងវិន័យបែបណាខ្លះ? ចម្លល់ទាំងនេះនឹងត្រូវបានបង្ហាញដូចខាងក្រោម ៖

### ៤.១ នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយដែលបានប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

17. សម្បថនេះត្រូវស្បថថា បំពេញមុខងារដោយស្មោះត្រង់״ មានគំរូនៅក្នុងឧបសម្ព័ន្ធ
18. នត្ថិភាព គឺភាវគ្មាន ឬ ភាពនៃអ្វីៗដែលមិនមាន (យោងតាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងទៅដល់ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ជូនចំពោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬ ភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីខាងវិន័យនេះ ។

### ៤.២ ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មិនខុសគ្នាទេចំពោះការដាក់ទណ្ឌកម្មខាងវិន័យសម្រាប់នាយទាហាន នៃកងរាជអាវុធហត្ថ និងនាយនគរបាលជាតិ ដូច្នេះមិនមែនជាឧបសគ្គទៅដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ក្នុងការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។ ដោយមូលហេតុ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវបានច្បាប់នេះ ផ្តល់នូវនីតិសម្បទាឱ្យក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះនៅពេលដែលពួកគាត់ប្រព្រឹត្តនូវកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួនពេល នោះបទបញ្ញត្តិដែលទាក់ទងទៅនឹង "កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ៤ ដល់ មាត្រា ៦៦ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

# ជំពូកទី២
# ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី២
# ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

តើនគរបាលយុត្តិធម៌ត្រូវមាននីតិវិធីយ៉ាងដូចម្តេចខ្លះ នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌមួយ? យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនគរបាលយុត្តិធម៌ គឺជាជំនួយរបស់តុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានដូចជា នីតិវិធីនៃការស៊ើបអង្កេត នីតិវិធីនៃការស៊ើបសួរ នីតិវិធីនៃការជំនុំជម្រះ និងនីតិវិធីមួយចំនួនទៀតដូចជានីតិវិធី ប្រតិបត្តិ និងនីតិវិធីដោយឡែក។ បើយើងពិនិត្យឱ្យបានលម្អិតចាប់ពីមាត្រា១ រហូតដល់មាត្រា ៦១២ នៃក្រមនីតិវិធីនេះ ឃើញថានគរបាលយុត្តិធម៌ត្រូវបំពេញមុខងារមួយចំនួនធំដូចបាន កំណត់យ៉ាងច្បាស់នៅក្នុងមាត្រាមួយចំនួនផ្សេងគ្នា គឺដើម្បីជួយសម្រួលដល់ស្ថាប័នអយ្យការតុលាការក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋដែលរងគ្រោះ។ នៅក្នុងដំណាក់នៃកាលស៊ើបអង្កេតនេះ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះរួចមក ជាបឋមត្រូវតែវាយតម្លៃអំពីប្រភេទនៃបទល្មើសជាមុនសិនថាតើជាបទល្មើសជាក់ស្តែង ឬ ជាបទល្មើសមិនជាក់ស្តែង? ហើយតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌អាស្រ័យលើប្រភេទនៃបទល្មើសទាំងពីរនេះ។ ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីចុះទៅកន្លែងកើតហេតុនោះភ្លាមៗ ឬ ស្វែងរកស្រាវជ្រាវកំណត់អត្តសញ្ញាណជនសង្ស័យដែលទើបនឹងរត់គេចពីកន្លែងប្រព្រឹត្តបទល្មើស ឬ ធ្វើការឆែកឆេរពីកន្លែងប្រព្រឹត្តបទល្មើស ដោយមិនចាំបាច់គោរពម៉ោង នីត្យានុកូលនៃការឆែកឆេរដូចករណីបទល្មើសមិនជាក់ស្តែងទេ (មានការអនុញ្ញាតពីព្រះរាជអាជ្ញា) ឬ ធ្វើការឃាត់ខ្លួនជនសង្ស័យ និងរាល់បុគ្គលដែលបានដឹងហេតុការណ៍ដោយនៅតែរឹងទទឹងមិនព្រមធ្វើជាសាក្សី ឬ ធ្វើការឃាត់ខ្លួនរាល់បុគ្គលដែលមានតម្រុយបានប្រព្រឹត្តបទល្មើស ទៅកាន់ការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃនគរបាលយុត្តិធម៌ ដើម្បីធ្វើកំណត់ហេតុក្នុងការ ស្តាប់ចម្លើយ រួចបញ្ជូនជននោះទៅអយ្យការ (តុលាការ) ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើចំណាត់ការបន្តបាន។ រីឯការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើរបាយការណ៍សុំបើកការស៊ើបអង្កេតបឋម ដោយខ្លួនឯងផ្ទាល់ ឬ តាមការចង្អុលបង្ហាញពីព្រះរាជអាជ្ញាសិនដើម្បីធ្វើការស្រាវជ្រាវ រកតម្រុយនៃបទល្មើស ដើម្បីឈានដល់ការកំណត់អត្តសញ្ញាណជនជាប់សង្ស័យរហូតឈានដល់វិធានការនៃឆែកឆេរដោយគោរពម៉ោង នីត្យានុ-កូលនៃការឆែកឆេរពីម៉ោង ៦ព្រឹក ដល់ម៉ោង ៦ល្ងាច និងធ្វើការឃាត់ខ្លួនជនជាប់សង្ស័យតាមរយៈការបញ្ជាឱ្យចូលខ្លួន (ដីកាកោះ ឬ ដីកាបញ្ជាឱ្យចូលខ្លួន) ដែលមានតម្រុយនៃបទល្មើស ដើម្បីធ្វើកំណត់ហេតុក្នុងការស្តាប់ចម្លើយ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាធ្វើចំណាត់ការ បន្តតាមនីតិវិធី។ ជាក់ស្តែងការពិនិត្យស្វែងរកបទល្មើស គឺយើងគួរបែកចែកជា ២ (ពីរ) ចំណុចសំខាន់តូចៗ មាន

ដូចជាការពិនិត្យរកបទល្មើសដោយខ្លួនឯង និងការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង ដូច្នេះខ្ញុំនឹងធ្វើការបង្ហាញជូនដូចតទៅ ៖

ទី១ ការពិនិត្យបទល្មើសដោយខ្លួនឯងនេះមានន័យថា ចំពោះមន្ត្រីនគរបាលយុត្តិធម៌នៅពេលដែលគាត់ឃើញកើតមានបទល្មើសជាក់ស្តែងចំពោះមុខ ឬ មិនជាក់ស្តែងគឺគាត់មានសិទ្ធិធ្វើកិច្ចការតាមដំណើរការនីតិវិធី ដោយខ្លួនឯងបានដោយពុំចាំបាច់មានបណ្តឹងពីប្រជាពលរដ្ឋឡើយ មានន័យថាជាបទល្មើសជាក់ស្តែង ដោយប្រើប្រាស់នីតិវិធីជាក់ស្តែងដែលច្បាប់បានកំណត់ក្នុងមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ទី២ ការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង គឺជាការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹង មានន័យថា នៅពេលដែលមាន បទល្មើសកើតឡើងមួយរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ពុំបានដឹងនូវហេតុការណ៍ទាំងនោះដូច្នេះ តើមន្ត្រីនគរបាលយុត្តិធម៌អាចទទួលបណ្តឹងពីអ្នកណាខ្លះ? ការទទួលបណ្តឹងនេះអាចទទួល បណ្តឹងពីប្រជាពលរដ្ឋដែលរងគ្រោះផ្ទាល់ ឬ ក៏ជាតតិយជនដែលបានដឹងអំពីហេតុការណ៍នៃបទល្មើសទាំងនោះ ឬ ក៏ជារបាយការណ៍របស់ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌[19] ដើម្បីស្វែងរកនូវយុត្តិធម៌ទៅឱ្យជនរងគ្រោះ។ នៅក្នុងបណ្តឹងនេះដែលខ្ញុំសូមធ្វើការបែងចែកជា ២ (ពីរ)គឺ ១. ប**ណ្តឹងទាមទារ** និងទី២. **បណ្តឹងបរិហារ** ៖

**តើអ្វីទៅជាបណ្តឹងទាមទារ?** បណ្តឹងទាមទារគឺសំដៅទៅលើបណ្តឹងរបស់ប្រជាពលរដ្ឋ ឬ ជាជនរងគ្រោះនៅក្នុងបទល្មើសណាមួយនោះគាត់ប្តឹងទៅស្ថាប័នមានសមត្ថកិច្ច គឺប្តឹងទៅនគរបាលយុត្តិធម៌តែម្តង ដើម្បីទាមទារឱ្យស្ថាប័នមានសមត្ថកិច្ចដោះស្រាយ ឬ ផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្ត និងទាមទារនូវសំណងការខូចខាត និងជម្ងឺចិត្តដែលបានប្រព្រឹត្តមកលើរូបគាត់ ។

**តើអ្វីទៅជាបណ្តឹងបរិហារ?** បណ្តឹងបរិហារ គឺសំដៅទៅលើបណ្តឹងវែកមុខបទល្មើសមានន័យថាបង្ហាញ ឬ ក៏បកអាក្រាតនូវបទល្មើស ដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ចគាត់ជាអ្នកមានសិទ្ធិនៅក្នុងការពិនិត្យ និងស្វែងរកភស្តុតាងនៅក្នុងបទល្មើសដើម្បីចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់។ បន្ថែមពីនេះទៅទៀតនៅក្នុងបណ្តឹងបរិហារអាចធ្វើឡើងជូនកាលដោយតតិយជន គឺជនដែលគាត់បានដឹងពីបទល្មើសហ្នឹង ហើយគាត់ប្តឹងបរិហារទៅមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចការនេះ ឬ ក៏ជូនកាលបណ្តឹងបរិហារនេះអាច ធ្វើឡើងដោយមន្ត្រីសាធារណៈដែលច្បាប់យើងបានកំណត់រួច ថាមន្ត្រីសាធារណៈមានកាតព្វកិច្ចនៅក្នុងការ

19. យោងតាមប្រសាសន៍របស់ ឯកឧត្តម ប៊ុន ហុន អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ធ្វើបណ្តឹងបរិហារប្រសិនជាគាត់បានដឹងអំពីបទល្មើសណាមួយ[20]។ ដើម្បីឱ្យងាយយល់ច្បាស់យើងនឹងធ្វើការបែងចែកចំណុចតូចៗជា ៤ ចំណុច ពាក់ព័ន្ធទៅនឹងការពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹងដូចតទៅ ៖

ទីមួយ ត្រូវការធ្វើកំណត់ហេតុទទួលពាក្យបណ្តឹងទាក់ទងទៅនឹងការទទួលបណ្តឹង នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវពាក្យបណ្តឹងនេះហើយ តើយើងត្រូវមានចំណាត់ការ ឬវិធានការដូចម្តេចខ្លះទៅលើពាក្យបណ្តឹងនេះ[21]? មុននឹងឈានដល់ការឆ្លើយសំនួរនេះយើងគួរស្វែងយល់ថានីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ នៅក្នុងក្របខណ្ឌការងារជាមន្ត្រី នគរបាលយុត្តិធម៌ **គឺការទទួលបណ្តឹងហ្នឹងហើយ**។ ហើយដើម្បីធានានូវប្រសិទ្ធិភាពនៃការងារដំណើរការរឿងក្តីព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌយើងបានកំណត់នូវវិធានការណ៍មួយចំនួនទាក់ទងនឹងចំណាត់ការលើពាក្យបណ្តឹងដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។ ជាដំបូងនៅពេល មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវពាក្យបណ្តឹង គឺចាំចាច់បំផុតគាត់ត្រូវតែធ្វើកំណត់ហេតុនៃការទទួលបណ្តឹង[22]។ គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះតម្រូវ ឱ្យមានការធ្វើកំណត់ហេតុ។ កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង[23]។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬ សាសនាថាខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍ ។ នៅក្នុងករណីណាក៏ដោយអ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាលជាតិ ឬ កងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តិការបានឡើយ។ កំណត់ហេតុស្តីអំពីការដាក់ពាក្យប្តឹងត្រូវមានដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌
- កាលបរិច្ឆេទ។

ទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង។ ការឆូត ការថែម និងការយោង ត្រូវតែបញ្ជាក់ដោយការចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹងនៅរឹមទំព័រ។ មុននឹងចុះហត្ថលេខា និងផ្តិតម្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណី

20. មាត្រា៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ (កាតព្វកិច្ចធ្វើបណ្តឹងបរិហារចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម)
21. ជាសំនួររបស់ អ្នកស្រី និង ធូក អ្នកសម្របសម្រួលទូរទស្សន៍ជាតិកម្ពុជា ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធី ព្រហ្មទណ្ឌ ឆ្នាំ ២០០៧
22. កំណត់ហេតុទទួលពាក្យបណ្តឹងមានគំរូនៅក្នុងឧបសម្ព័ន្ធ របស់ការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃមន្ទីរយុត្តិធម៌ អង្គភាពបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
23. អ្នកប្តឹង អាចជាជនរងគ្រោះផ្ទាល់ ឬ តតិយជនដែលបានដឹងអំពីហេតុការណ៍នៃបទល្មើស ឬ ជារបាយការណ៍ភ្នាក់ងារួម ន្ត្រីនគរបាលយុត្តិធម៌

ចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសម្លេងខ្លាំងៗ[24]។ ចំពោះអ្នកបកប្រែនេះត្រូវមានលក្ខណៈឯករាជ ឬ ក្រៅអង្គភាពសាមុី កាលណាមានមន្ត្រីនគរបាល យុត្តិធម៌ខ្លួនឯងបកប្រែ គឺនាំអោយមោឃៈភាពនូវកំណត់ហេតុ[25]។

បញ្ជីទទួលពាក្យបណ្តឹង នៅក្នុងក្របខណ្ឌនេះដែរដើម្បីធានានូវប្រសិទ្ធិភាព ដើម្បីឱ្យអាជ្ញាធរតុលាការ ជាពិសេសគឺព្រះរាជអាជ្ញាដែលមានតួនាទីសំខាន់ជាអ្នកដឹកនាំក្នុងការងារសម្របសម្រួល និងដឹកនាំការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ គ្រប់អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ត្រូវមានបញ្ជីទទួលពាក្យបណ្តឹង។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវ និទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង
- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង
- ប្រភេទនៃអំពើដែលប្តឹង
- ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬ ក៏ផ្តើមធ្វើការស៊ើបអង្កេត។

បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[26]។មានន័យថានៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ ទទួលបានបណ្តឹងហើយនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញា ឬ ក៏មន្ត្រីនគរបាលយុត្តិធម៌នោះធ្វើការស៊ើបអង្កេតបឋមជាមុនសិន? ចំណាត់ការបន្តពីការដាក់ពាក្យបណ្តឹង គឺមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលពាក្យបណ្តឹងនោះ ត្រូវតែចាត់ការបណ្តឹងនោះភ្លាមៗ ធ្វើការស៊ើបសួរ ឬ ក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។ មន្ត្រីនគរបាលយុត្តិធម៌មុននឹងធ្វើការស៊ើបអង្កេតអាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។ កាលណាទទួលពាក្យបណ្តឹងបរិហារដែលមានបង្ហាញពីមូលហេតុជាក់ច្បាស់សមហេតុផលមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ ដើម្បីធ្វើការបើកការស៊ើបអង្កេតក្នុងរឿងក្តីនេះ[27]។ នៅពេលដែលគាត់(មន្ត្រីនគរបាលយុត្តិធម៌) ទទួលបណ្តឹង គឺមានន័យថា គាត់ត្រូវតែចាត់ការបណ្តឹងនោះភ្លាមៗ គឺធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញា ព្រោះថាមានតែព្រះរាជអាជ្ញាទេជាម្ចាស់ នៅក្នុងបណ្តឹង

24. មាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
25. យោងតាមប្រសាសន៍ ឯកឧត្តម ផូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
26. មាត្រា ៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
27. មាត្រា ៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

បានហើយជាអ្នកដឹកនាំសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ ហើយមានករណីមួយចំនួន នគរបាលយុត្តិធម៌មានសិទ្ធិអាចធ្វើការស៊ើបអង្កេតដោយឯកឯង នៅពេលបានទទួលបណ្ដឹង ឬ សុំការណែនាំពីព្រះរាជអាជ្ញា ប៉ុន្តែមានករណីខ្លះ គឺច្បាប់បានកំណត់ថា នៅក្នុងករណីបទឧក្រិដ្ឋ គឺចាំបាច់ត្រូវសុំការណែនាំរបស់ព្រះរាជអាជ្ញា។ ដូចយើងបានដឹងហើយថានៅ ក្នុងមាត្រា ៧៤ វាក្យខណ្ឌទី៣ បានកំណត់ថា "កាលណាទទួលពាក្យបណ្ដឹងបរិហារដែលមាន បង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ" ដូច្នេះបើសម្រាប់ការទទួលបណ្ដឹងទាមទារ គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯងបាន។ បញ្ជាក់ជាថ្មីម្តងទៀត ប្រសិនបើទទួលបណ្ដឹងបរិហារ ត្រូវតែសុំជូនព័ត៌មាន ឬ រាយការណ៍ទៅកាន់ព្រះរាជអាជ្ញា និងសុំការណែនាំពីព្រះរាជអាជ្ញា។ ការជូនពត៌ ឬ របាយការណ៍នេះមានន័យថា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ ទទួលបណ្ដឹងបរិហារ ឬ គេអាចហៅម្យ៉ាងទៀតបានថា ការទទួលបណ្ដឹងមិនជាក់ស្ដែង ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍សុំបើកស៊ើបអង្កេតបឋម[28] ពីព្រះរាជអាជាជ្ញា។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាបណ្ដឹងដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនទៅ មានពិរុទ្ធភាពនៃបទល្មើសប្រាកដមែននោះ គឺព្រះរាជអាជ្ញានឹងបោះត្រាអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតតាមការស្នើសុំអនុវត្តតាមមាត្រា៣៧[29] ៤០[30]៧៤[31] ១១១[32] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ការបំពានលើសកម្មភាពតុលាការ គឺសំដៅទោះក្នុងករណីបែបណាក៏ដោយមន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានទេទោះបីជា ក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើសនិងជនរងគ្រោះ ឬ ក៏មានការដកបណ្ដឹងរបស់ជនរងគ្រោះក៏ដោយ។ ពីព្រោះថាជាគោការណ៍បណ្ដឹងអាជ្ញា មិនអាចធ្វើការដោះស្រាយដោយការ សម្របសម្រួលទេ នេះជាគោលការណ៍ដែលបានកំណត់នៅក្នុងមាត្រា២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺថាជនរងគ្រោះអាចលះបង់មិនធ្វើបណ្ដឹងសុំទាមទារសំណងជម្ងឺចិត្ត ឬ ដកបណ្ដឹងរបស់ខ្លួនបាន។ ការលះបង់មិនប្ដឹងនឹងដកពាក្យប្ដឹងរបស់ជនរងគ្រោះនៅតែមិនអាចបញ្ឈប់ ឬ ព្យួរការអនុវត្តនៃបណ្ដឹងអាជ្ញាបានទេ។ លើកលែងបញ្ញត្តិចំណុចទី២ នៃមាត្រា៨[33] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មន្ត្រីនគរបាលយុត្តិធម៌ដែល

28. គំរូរាយការណ៍សុំបើកអង្កេតបឋម ចេញពីមន្ត្រីនគរបាលយុត្តិធម៌ នៃការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃកងរាជអាវុធ ហត្ថរាជធានីភ្នំពេញ មានក្នុងឧបសម្ព័ន្ធ
29. អំណាចរបស់ព្រះរាជអាជ្ញា
30. ជម្រើសនៃការចោទប្រកាន់
31. ចំណាត់ការបន្តនៃការដាក់ពាក្យបណ្ដឹង
32. ការបើកការស៊ើបអង្កេតបឋម
33. មូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញា

រក្សាទុកកំណត់ហេតុ ឬ វត្ថុតាងដោយចេតនា ឬ លាក់បំបាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុ ឬ វត្ថុតាងត្រូវចាត់ទុកថាមន្ត្រីនគរបាលយុត្តិធម៌នេះ បានប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌពាក់ព័ន្ធ និងជំពូកស្តីពីការស្រាវជ្រាវរកវត្ថុតាង[34]។ ក្នុងករណីខាងលើនេះមន្ត្រីនគរបាលយុត្តិធម៌អាចជាប់ចោទពីបទលុបបំបាត់វត្ថុតាង[35] ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌រក្សាទុកកំណត់ហេតុ ឬ វត្ថុតាងដោយចេតនា ឬ លាក់បំបាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុនោះ ឬវត្ថុតាងទាំងនោះ[36]។ ជាថ្មីម្តងទៀតពាក់ព័ន្ធនឹងបណ្តឹងកន្លងមកមានពាក្យអាចាមរ៉ាមថា ពាក្យបណ្តឹងលើសពី២៤ម៉ោងអស់ប្រសិទ្ធិភាព? តើនេះជាការពិត ឬ យ៉ាងណានោះខ្ញុំនឹងធ្វើការបកស្រាយដូចតទៅ ៖

**<u>សូមចងចាំ</u>** ៖ នៅក្នុងក្របខណ្ឌនៃការទទួលពាក្យបណ្តឹង ដែលគេដាក់នៅមន្ត្រីនគរបាលយុត្តិធម៌គឺ ច្បាប់ពុំបានកំណត់ថាលើសពី២៤ម៉ោង អស់ប្រសិទ្ធិភាព ឬ អត់ទទួលបណ្តឹងនោះទេ ព្រោះថាច្បាប់ បានកំណត់នូវកាតព្វកិច្ច គឺនៅពេលដែលបានទទួលពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែចាត់ការភ្លាមៗបញ្ជូនរឿងទៅព្រះរាជអាជ្ញា ឬ ក៏ធ្វើការស៊ើបអង្កេតហើយនៅពេលដែលករណីបញ្ជូនរឿងទៅព្រះរាជអាជ្ញាហ្នឹង គឺច្បាប់គេបានកំណត់រយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលទទួលពាក្យបណ្តឹង[37] មានន័យថា នៅពេលដែលបណ្តឹងរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅដល់ព្រះរាជអាជ្ញាបន្ទាប់មករយៈពេល២ (ពីរ) ខែ ជនរងគ្រោះអត់បានទទួលចម្លើយ ឬ ក៏ស្ងាត់ស្ងៀមពីព្រះរាជអាជ្ញាអមសាលាដំបូង គឺជនរងគ្រោះអាចដាក់ពាក្យបណ្តឹងប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[38] ក្នុងករណីនេះ គឺដើម្បីពិនិត្យ តើថាចំណាត់ការនៃពាក្យបណ្តឹងដែលដាក់ជូនទៅព្រះរាជអាជ្ញាដល់ណាហើយ? នេះជាចំណាត់ការមួយដែលចាត់ការទៅតាមនីតិវិធីដើម្បីជៀសវាងភាពអសកម្ម របស់អាជ្ញាធរមានសមត្ថកិច្ចដែលចូលរួមក្នុងការស៊ើបអង្កេត[39]។ ដូច្នេះសរុបមកវិញពាក្យអាចាមរ៉ាម ថាបណ្តឹងលើសពី២៤ម៉ោង អស់ប្រសិទ្ធិភាពពុំត្រឹមត្រូវទេ ហើយក៏គ្មានមូលដ្ឋានច្បាស់លាស់ផងដែរ។ ព្រោះពាក្យអាចាមរ៉ាមថាបណ្តឹងលើសពី ២៤ ម៉ោង វាផ្ទុយពីមាត្រា៦ កថាខណ្ឌទី២ នៃក្រមនេះ។

34. មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

35 មាត្រា៥៣៣ នៃក្រមព្រហ្មទណ្ឌ អនុម័តថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩

36. យោងតាមប្រសាសន៍ ឯកឧត្តម ផូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ក្នុងកម្មវិធី ផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

37. មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

38. មាត្រា៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

39. យោងតាមប្រសាសន៍ ឯកឧត្តម ផូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយ ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី១ សិទ្ធិអំណាចនៅក្នុងការស៊ើបអង្កេត

នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ចែកចេញជា ២ (ពីរ) គឺ ទីមួយ គឺកាស៊ើបអង្កេតករណីជាក់ស្តែង បើនិយាយឱ្យសាមញ្ញទៅ កាស៊ើបអង្កេតករណី ជាក់ស្តែង គឺសំដៅដល់ការស៊ើបអង្កេតក្នុងករណីដែលមានបទល្មើសជាក់ស្តែង។ ទីពីរ ការស៊ើបអង្កេតបឋម បើនិយាយឱ្យសាមញ្ញទៅ ការស៊ើបអង្កេតបឋម គឺសំដៅដល់ការស៊ើបអង្កេតក្នុងករណី ដែលមាន បទល្មើសមិនជាក់ស្តែង។ នៅក្នុងច្បាប់បានកំណត់យ៉ាងច្បាស់ថា អំណាចទាំងឡាយដែលផ្តល់ឱ្យ មន្ត្រីនគរបាលយុត្តិធម៌ខុសគ្នា ទៅតាមពេលដែលមន្ត្រីនោះបំពេញការនៅក្នុងក្របខណ្ឌ នៃការស៊ើប អង្កេតជាក់ស្តែង ឬ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម[40]។ តាមអត្ថន័យនេះដែរ យើងអាចទាញ បានថា ការស៊ើបអង្កេតទាំងពីរនេះគឺមិនដូចគ្នាទេទាំងលក្ខខណ្ឌនៃការបើកការស៊ើបអង្កេតក៏មិនដូច គ្នាទាំងអំណាចដែលប្រើប្រាស់ដោយ មន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតនេះ ក៏ខុសគ្នាដែរ។ ដូច្នេះដើម្បីយល់ឱ្យកាន់តែច្បាស់ យើងខ្ញុំនឹងលើកយកចំណុច នីមួយៗមកពិភាក្សា ដូចខាងក្រោម ៖

### កថាខណ្ឌទី១ ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង

នីតិវិធីនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងមានច្រើន ចំណុចសំខាន់ៗ ដែលយើងនឹងធ្វើការបកស្រាយប៉ុន្តែមុននឹងធ្វើការបកស្រាយឱ្យបានលម្អិតអំពីនីតិ វិធីរបស់នគរបាលយុត្តិធម៌ចំពោះការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ទាល់តែយើងយល់ ឱ្យបានច្បាស់ជាមុនសិនថា តើអ្វីទៅជាបទល្មើសជាក់ស្តែង ?

#### ១.១ និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង[41]

ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវមូលដ្ឋាន ២ (ពីរ) សម្រាប់ធ្វើការពិនិត្យ និងកំណត់ស្ថានភាព ដែលក្នុងនោះមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់នៅក្នុងស្ថានភាពនៃការស៊ើបអង្កេតជាក់ស្តែងបាន៖

ទីមួយ នៅក្នុងមាត្រា៨៦ បានផ្តល់ជានិយមន័យអំពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង។ មាត្រានេះបានចែងថា បទឧក្រិដ្ឋ ឬ មជ្ឈិមជាក់ស្តែងគឺ ស្ថិតនៅក្នុងសកម្មភាពដូចតទៅ ៖

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ហើយបានបញ្ជាក់បន្ថែមនៅក្នុងកថាខណ្ឌបន្ទាប់ថា
- ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមាន

40. មាត្រា៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

41. យោងតាមប្រសាសន៍ ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បទល្មើសរួចបន្តិចមក

- ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភីង
- បុគ្គលដែលត្រូវគេរកឃើញថាមានវត្ថុ ឬ ស្លាកស្នាម ឬ តម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស។ ហេតុនេះហើយ ស្ថានភាពដែលមានដូចនៅក្នុងមាត្រា៨៦ នេះគឺជាស្ថានភាព ករណីបទល្មើសជាក់ស្តែង។ នៅក្នុងករណីដែលបទល្មើសមួយប្រព្រឹត្តនៅក្នុងស្ថានភាពណាមួយនៃស្ថានភាពដែលបានចែងនៅក្នុងមាត្រា ៨៦ នេះ គឺក្នុងករណីនោះយើងចាត់ទុកថាជាបទល្មើសជាក់ស្តែង ហើយមន្ត្រីនគរបាលយុត្តិធម៌គាត់អាចបើការស៊ើបអង្កេតជាក់ស្តែងបាន។

ទីពីរ ផ្អែកលើមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះក៏ជាលក្ខខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងដែរ។ នៅក្នុងមាត្រានេះបានចែងបញ្ជាក់ជូនថា«ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា៨៦ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈឹមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

**<u>ឧទាហរណ៍</u>** លោក វិចិត្ត ជាអ្នករកស៊ីដ៏ល្បីនៅក្នុងរាជធានីភ្នំពេញ គាត់មានដីចំការជាច្រើនកន្លែងតាមបណ្តាលខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា។ នៅដើមខែមករា មានឈ្មួញម្នាក់ចង់ទិញចំការរបស់គាត់ ដែលស្ថិតនៅខេត្តព្រះវិហារ បន្ទាប់មកក៏ណាត់គ្នាទៅពិនិត្យមើលដីចំការនោះទាំងអស់គ្នា។ លុះពេលទៅដល់ក៏ស្រាប់តែប្រទះឃើញ សាកសពបុរសម្នាក់បានស្លាប់នៅលើដីចំការរបស់គាត់ ដោយមិនដឹងមូលហេតុអ្វីឡើយ។ ភ្លាមៗនោះលោក វិចិត្ត ក៏បានរត់ទៅប្រាប់ដល់ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌អំពីបញ្ហានេះ។ ក្រោយមកភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ក៏បានរាយការណ៍យ៉ាងលឿនទៅមន្ត្រីនគរបាលយុត្តិធម៌ដែលជាប្រធានឋានានុក្រមរបស់ខ្លួន។ បន្ទាប់ពីបានទទួលនូវ ការរាយការណ៍អំពីអង្គហេតុនេះរួចហើយមន្ត្រីនគរបាលយុត្តិធម៌ ក៏បានចុះមកពិនិត្យ និងធ្វើការឆែកឆេរនៅចំណុចដីចំការរបស់លោក វិចិត្ត តែម្តង។ នៅក្នុងករណីខាងលើនេះជាការពិតពីដំបូងគឺយើងឃើញថា ជាបទល្មើសមិនជាក់ស្តែងប៉ុន្តែដោយសារតែសកម្មភាពនោះបានគោរពនូវលក្ខខណ្ឌនៃមាត្រា៨៨ ត្រង់ចំណុចថា លោក វិចិត្ត ដែលជាម្ចាស់កាន់កាប់ដីចំការកើតហេតុខាងលើបានសុំឱ្យ

ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ហើយភ្នាក់ងារគាត់បានបំពេញដូច លក្ខខណ្ឌក្នុងវាក្យខណ្ឌចុងក្រោយនៃមាត្រា៨៨។ ដូច្នេះក្នុងករណីនេះយើងអាចនិយាយបានថា វាជាបទល្មើសជាក់ស្តែងស្របតាមមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជារួមយើងអាចទាញបានថា លក្ខខណ្ឌនៃការបើកការស៊ើបអង្កេតជាក់ស្តែងមាន ២ គឺ ៖

ទីមួយ គឺបទល្មើសជាក់ស្តែងដែលមានចែងនៅក្នុងមាត្រា៨៦

ទីពីរ គឺការចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែលមានចែងនៅក្នុងមាត្រា៨៨

ហេតុនេះបើសិនមិនចូលក្នុងលក្ខខណ្ឌ ឬ ស្ថានភាពមានចែងនៅក្នុងមាត្រា៨៦ ឬ ស្ថានភាពដែលមានចែងក្នុងមាត្រា៨៨ កាលណាដែលនគរបាលយុត្តិធម៌គាត់ចាប់ផ្តើមធ្វើការស៊ើបអង្កេតជាករណីជាក់ស្តែង ដូច្នេះធ្វើឱ្យមានបញ្ហាទៅដល់ កិច្ចនីតិវិធីនៃការស៊ើបអង្កេតរបស់គាត់ មានន័យថាបើគាត់ស៊ើបអង្កេតករណីនេះ មិនមែនជាករណីជាក់ស្តែងប៉ុន្តែគាត់យកវិធាននៃការស៊ើបអង្កេតករណីជាក់ស្តែងយកមកអនុវត្ត គឺ ក្នុងករណីនេះធ្វើឱ្យកិច្ចស៊ើបអង្កេតរបស់គាត់អាចទទួលនូវមោឃភាពពីតុលាការ មានន័យថាមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់បាននោះទេ។ ដូច្នេះនៅក្នុងករណីនេះ ត្រូវតោងយល់ឱ្យបានច្បាស់នៅក្នុងស្ថានភាពនៃមាត្រា៨៦ និងមាត្រា៨៨។ បើយើងពិនិត្យនៅក្នុងមាត្រា៨៦ យើងបានឃើញថាមាន ៤ សម្មតិកម្ម លើស្ថានភាពនៃបទល្មើសជាក់ស្តែង៖

ទីមួយ គឺបទល្មើសដែលកំពុងប្រព្រឹត្ត នៅក្នុងស្ថានភាពនេះ ឬ នៅក្នុងអត្ថន័យនេះអាចយល់ បានថាសំដៅទៅលើស្ថានភាពមួយដូចជាជនម្នាក់កំពុងតែវាយតប់គ្នា។ ដូច្នេះស្ថានភាពដែលយើងកំពុងតែឃើញគឺចាត់ទុកថាជាស្ថានភាពដែលកំពុងប្រព្រឹត្តបទល្មើសនេះហើយ។

ទីពីរ គឺស្ថានភាពដែលទើបប្រព្រឹត្តរួចភ្លាមនេះ គឺអាចយល់បានថាក្រោយពេលដែលប្រព្រឹត្តរួចភ្លាមៗតែម្តង ដូចជាគាត់បាញ់គេស្លាប់នៅហ្នឹងកន្លែងតែម្តង ដូចនេះពេលដែលបាញ់គេរួចហើយ គឺបទល្មើសបានកើតមានឡើង ម្យ៉ាងទៀតគាត់មានវត្តមាននៅនឹងកន្លែងកើតហេតុ នេះចាត់ទុកថា ជាស្ថានភាពដែលទើបប្រព្រឹត្តរួចភ្លាម។

ទីបី គឺនៅពេលដែលយើងប្រើពាក្យថា ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែរកាលណាក្រោយពេលមានបទល្មើសរួចមកកន្លែងនេះមានសំនួរសួរច្រើនណាស់ ពេលខ្លះសួថាតើប្រព្រឹត្តរួចភ្លាមហើយ និងបទល្មើសរួចបន្តិចមកខុសគ្នាដូចម្តេច? តាមពិតបើយើងពិនិត្យក្នុងស្ថានភាពនៃកថាខណ្ឌ១ នេះយើងត្រូវពិនិត្យអំពីស្ថានភាពនៃច្បាប់ជាមុនសិន គឺសំដៅជាពិសេសទៅលើច្បាប់ព្រហ្មទណ្ឌក្នុងសម័យអន្តរកាល ដែលយើងហៅជាទូទៅថាជាច្បាប់អ៊ុនតាក់ (UNTAC) ច្បាប់នេះមានចែងក្នុងមាត្រា១៨ ដែលបានកំណត់អំពី និយមន័យនៃបទល្មើសជាក់ស្តែងដូចគ្នា

ហើយក្រមនីតិវិធីថ្មីយើង គឺបានចែងនៅកន្លែងនេះថា កាលណានៅក្រោយពេលដែលមានបទល្មើសរួចបន្តិចមក គឺសំដៅដល់ស្ថានភាពទី២ និងបីនៃមាត្រា១៨ នៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលបានបញ្ញត្តិថា បើជនសង្ស័យត្រូវបានសាក្សី ឬ ជនរងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬ បទល្មើសថាជាឧក្រិដ្ឋជន មានន័យថា ជនម្នាក់នោះទើបប្រព្រឹត្តបទល្មើសរួចបន្តិចមក ហើយគាត់ហ្នឹង ស្ថិតនៅក្នុងហ្វូងមហាជនដែលកំពុងចោមរោម ឯជនរងគ្រោះ ឬ សាក្សីដែលបានឃើញចង្អុលប្រាប់ថាលោកហ្នឹងគឺជាអ្នកប្រព្រឹត្តបទល្មើសបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង។ ស្ថានភាពមួយទៀតដែលមាត្រា១៨ (ច្បាប់អ៊ុនតាក់) មានបញ្ជាក់ជូនថា បើជនសង្ស័យនោះរកវិធីរត់គេចពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស។ ដូច្នេះក្រោយពេលដែលប្រព្រឹត្តរួចបន្តិចមក គឺគាត់រកវិធីគេចខ្លួន ហើយនៅពេលដែលគាត់រកវិធីគេចខ្លួននោះ ស្ថានភាពនេះច្បាប់យើងបានចែងថាជាប្រភេទនៃស្ថានភាពដែលស្ថិតនៅក្នុងមាត្រា៨៦ មានន័យថាជាបទល្មើសជាក់ស្តែង។

ទីបួន ក្រៅពីនេះ មាត្រា៨៦ ក៏បានបញ្ជាក់ផងដែរថាត្រូវចាត់ទុកថាជាបទល្មើស ជាក់ស្តែងផងដែរ គឺពេលដែលជនសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រជាប់ចាប់ប្រភឹង ហើយន័យនេះនៅក្នុងវចនានុក្រមខ្មែររបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** បានបញ្ជាក់យ៉ាងច្បាស់ថាពាក្យ "ដេញប្រជាប់ចាប់ប្រភឹង" មានន័យល្អណាស់ គឺសំដៅទៅដល់ការដេញយ៉ាងប្រកិត ហើយចាប់បានជនល្មើសនោះបានតែម្តង ដូច្នេះស្ថានភាពនេះ វាជាក់ស្តែងណាស់ និងបញ្ជាក់យ៉ាង ច្បាស់ថាក្នុងករណីនេះគឺ មិនអាចស្ថិតក្នុងស្ថានភាពដែលគាត់រត់ទៅឆ្ងាយហើយបាំងខ្លួនគាត់នោះទេ គឺយើងដេញយ៉ាងប្រកិតជាមួយជនល្មើស ហើយចាប់ជនហ្នឹងបាននៅក្នុងស្ថានភាពនេះតែម្តង។ មួយផ្សេងទៀតគឺ បុគ្គលដែលត្រូវបានគេរកឃើញថាមានវត្ថុ ឬ មានស្លាកស្នាម ឬ តម្រុយយ៉ាងច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេ សន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស។

__**ឧទាហរណ៍**__ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោងប្រមាណ២១ និង៣០នាទីនៅគល់ស្ពាន ឧកញ៉ា លីយ៉ុងផាត់ ត្រើយខាងកើត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មានករណីឃាតកម្ម មួយបានកើតឡើង ភ្លាមនោះក៏មានប្រជាពលរដ្ឋដែលស្ថិតនៅ ក្នុងហេតុការណ៍នោះបានរាយការណ៍មក មន្ត្រីនគរបាលយុត្តិធម៌ជួយអន្តរាគមន៍ភ្លាម។ ភ្លាមនោះក៏ឃើញមានមន្ត្រីជំនាញខាងកោសល្យវិច័យធ្វើការត្រួតពិនិត្យនៅកន្លែងកើតហេតុ និងសាកសពជនរងគ្រោះឃើញថានៅលើដងខ្លួនសាកសព មានស្នាមធ្លុះដោយសារផ្លែកាំបិតជាច្រើនកន្លែង និងមានឈាមប្រឡាក់ដាបពាសពេញផ្លូវថ្នល់។ ក្រោយពេលពិនិត្យរួចហើយមន្ត្រីនគរបាលយុត្តិធមិ នៃកងរាជអាវុធហត្ថបានចាប់ផ្តើមបើកការស៊ើបអង្កេតលក្នុងករណីជាក់ស្តែងនោះតែម្តង។ ខណៈនោះ

ស្រាប់តែមានជនគួរឱ្យសង្ស័យម្នាក់មានកាំបិតនៅក្នុងដៃ ហើយអាវប្រឡាក់សុទ្ធតែឈាមផងដែរ បានរត់ចេញពីកន្លែងកើតហេតុ ចូលទៅក្នុងព្រៃភ្លាមនោះក៏មានប្រជាពលរដ្ឋជួយដេញប្រដាប់ចាប់ប្រភីងយកមកឱ្យកម្លាំងជំនាញមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការសាកសួរ។ ដោយសារតែជននោះនៅក្បែរនោះផង ពេលឃើញស្ថានភាពដូចនេះយើងអាចសន្និដ្ឋានជាដំបូងបានថាគាត់បានប្រព្រឹត្តបទល្មើស ដែលស្ថិតនៅក្នុងប្រភេទនៃបទល្មើសជាក់ស្តែង។ ដូច្នេះស្ថានភាពទាំងអស់ខាងលើនេះគេអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតជាក់ស្តែង គឺអនុញ្ញាតឱ្យគាត់ប្រើប្រាស់អំណាចដ៏ធំធេងមួយចំនួននៅក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង។ បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌយើង បានបញ្ជាក់ជូននៅក្នុងមាត្រា១០៦ ថារយៈពេលមានទៅដល់ ៧ថ្ងៃ (ប្រាំពីរ) ឯណោះ គឺនៅពេលដែលសកម្មភាព នៃការស៊ើបអង្កេតនោះមានជាប់ជានិច្ច ឬជាប់ គ្មានឥតដាច់។ ម្យ៉ាងវិញទៀត នៅក្នុងបទល្មើសជាក់ស្តែងនេះក្រមនីតិវិធីបញ្ជាក់ច្បាស់ណាស់ហើយដែល ខុសពីច្បាប់មុន គឺពុំបានបញ្ជាក់ជូនក្នុងមាត្រ៨៦ និង៨៨ នេះគ្រប់ជនទាំងអស់ដែលបានឃើញជនល្មើសគឺមានសិទ្ធិចាប់ខ្លួនហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ ដែលនៅជិតបំផុត[42]។ ការចាប់ខ្លួននេះមិនអាចចាត់ទុកថាជាការរំលោភលើសិទ្ធិបុគ្គលបានឡើយ ផ្ទុយទៅវិញប្រសិនបើជននោះមិនបានប្រព្រឹត្តបទល្មើសជាក់ស្តែង ហើយជននោះត្រូវបានចាប់ខ្លួន នោះយើងនឹងអាចប្រឈមក្នុងនាមជាបុគ្គល ឬ មួយជាមន្ត្រី ក៏អាចប្រឈមមុខជាមួយនឹងការផ្តន្ទាទោសដោយចោទប្រកាន់ពីករណីទាក់ទងនឹងការរំលោភ លើសិទ្ធិបុគ្គលដូចមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន។

**កំណត់សម្គាល** មាត្រា៨៦នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌចែងចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ដូច្នេះមិនអាចយកមាត្រានេះ មកប្រើប្រាស់ចំពោះបទលហុជាក់ស្តែងឡើយ[43]។ បន្ទាប់ពីបានយល់ច្បាស់អំពីនិយមន័យ នៃបទល្មើសជាក់ស្តែងរួចមក យើងនឹងលើកយកនូវបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីបទល្មើសជាក់ស្តែងមកបង្ហាញត្រង់ចំណុចវិធានការស្រាវជ្រាវដូចតទៅ

### ១.២ វិធានការស្រាវជ្រាវ

វិធានការនេះមានកំណត់ចាប់ពីមាត្រា៨៩ដល់មាត្រា៩៤។ បើផ្អែកតាម មាត្រា៩០ (កំណត់ហេតុលើការស្រាវនិងពិនិត្យ) មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវនិងការពិនិត្យរបស់ខ្លួន។ ដូច្នេះដើម្បីឱ្យងាយយល់យើងខ្ញុំសូមធ្វើការបង្ហាញជូន នូវវិធានការទាំងនោះតាម

42. មាត្រា៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

43. យោងតាមប្រសាសន៍របស់ មេធាវី គី ប៊ុនទ្រាន សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នាពេលផ្តល់បទសម្ភាសន៍ ជាមួយអ្នករៀបរៀង

លំដាប់លំដោយដូចតទៅ ៖

**១.២.១ វិធានភាដំបូងក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង**

ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ ចុះទៅកាន់ទីកន្លែងកើតហេតុដើម្បីធ្វើការពិនិត្យ និងស្រាវជ្រាវកំណត់រកមុខសញ្ញានៃបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងនឹងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ដើម្បីជៀសវាងបាត់ដាន។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនបាន គឺដើម្បីរក្សាសភាពដើមនៅកន្លែងកើតហេតុ ព្រោះបុគ្គលខ្លះគាត់អាច នឹងមានការពាក់ព័ន្ធ ឬ អាចផ្តល់ជាពត៌មានជាក់លាក់ណាមួយអំពីព្រឹត្តិការណ៍ទាំងនោះជូនដល់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីនេះដែរ ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ពាក្យថាប្រយោជន៍ ត្រង់ចំណុចនេះមានន័យថា ប្រសិនបើរឿងហេតុនោះមានតម្រុយច្បាស់លាស់ហើយកំណត់មុខសញ្ញាបានហើយ តែមន្ត្រីនគរបាលយុត្តិធម៌ មិនអាចចាត់ការបាននោះ ដូច្នេះត្រូវការព្រះរាជអាជ្ញាចុះ ទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេតផ្ទាល់តែម្តង។ ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាត ឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិទាំងមូលដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងច្បាប់ជាធរមាន។

**១.២.២ ការឆែកឆេរ**

សូមបញ្ជាក់ជូនថាកាឆែកឆេរ ត្រូវតែគោរពឱ្យបានតឹងតែងបំផុតទៅលើលក្ខខណ្ឌ និងនីតិវិធីដែលចែងក្នុងមាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រានេះបញ្ជាក់ជូនមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌មិនចាំបាច់មានដីកាពី តុលាការទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាត ជាបឋមពីព្រះរាជអាជ្ញាហើយការអនុញ្ញាតអាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់។ ដូច្នេះនៅពេលដែលគាត់បានទទួលការអនុញ្ញាតជាបឋម គឺមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានដែលការឆែកឆេរត្រូវគោរពនូវ លក្ខខណ្ឌមួយចំនួនដូចជាការឆែកឆេរត្រូវធ្វើជាទូទៅនៅមុខអ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខសាក្សីចំនួន ០២ (ពីរ) រូប ដែលសាក្សីនោះ ត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលបានចុះដឹកនាំប្រតិបត្តិការ។ យោងតាមគោលការណ៍ដែលមានចែងនេះ គឺត្រូវជ្រើសរើសអ្នកដែលមិនមានជាប់ពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការ មានន័យថាសាក្សីមិនមែនជានគរបាល ឬ ក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ដូច្នេះហើយ សាក្សីត្រូវជ្រើសរើសចេញពីអ្នកដែលមិនបានចូលរួមក្នុងប្រតិបត្តិការនៃ

ការឆែកឆេរនោះ។ ចំណុចមួយផ្សេងទៀត គឺទាក់ទងនឹងម៉ោងសម្រាប់ធ្វើការឆែកឆេរមន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ដូច្នេះលើកលែងតែមានករណីដូចជា ៖

- ក្នុងករណីដែលចែងដោយមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ
- ក្នុងករណីមានចែងដោយមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ
- ក្នុងករណីមានសម្រែកឱ្យគេជួយពីក្នុងទីកន្លែង
- ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជនគឺសំដៅទៅដល់ទីតាំងដែលបើកអាជីវកម្ម នៅពេលយប់ដូចជា បនល្បែង បនពេស្យា ក្លឹប ខារ៉ាអូខេ ឬ រង្គសាលរាំកម្សាន្តផ្សេងៗជាដើម គឺអាចធ្វើការឆែកឆេរបានព្រោះគេបើកចំហដល់សាធារណជននៅពេលយប់ ខុសពីម៉ោងឆែកឆេរពីម៉ោង៦ ព្រឹក ដល់ម៉ោង៦ ល្ងាច ដូច្នេះអាចធ្វើការឆែកឆេរដោយមិនគោរព លក្ខខណ្ឌពេលវេលានៃការឆែកឆេរបាន។
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀននេះគឺជាវិធានពិសេសមួយដែលទាក់ទងនឹងបទល្មើសគ្រឿងញៀនគឺពុំចាំបាច់គោរពវិធានទាក់ទង នឹងពេលវេលាចាប់ពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាចឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរ[44]ដែលនៅក្នុងនោះមានចុះ ៖

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ។

លក្ខខណ្ឌពិសេស ដោយមានវិជ្ជាជីវៈមួយចំនួនដែលត្រូវបានគាំពារជាពិសេសដោយច្បាប់។ ដូច្នេះការឆែកឆេរត្រូវគោរពនូវលក្ខខណ្ឌពិសេសនេះក្នុងនោះ សំដៅដល់វិជ្ជាជីវៈចំនួន ០២ (ពីរ) គឺ **វិជ្ជាជីវៈមេធាវី និងវិជ្ជាជីវៈសារព័ត៌មាន**។ ផ្លូវច្បាប់បានគាំពារវិជ្ជាជីវៈទាំងនេះក្នុងក្របខណ្ឌនីតិវិធីព្រហ្មទណ្ឌដោយបានហាមឃាត់មន្ត្រីនគរបាលយុត្តិធម៌មិនឱ្យ ធ្វើការឆែកឆេរចំពោះការិយាល័យមេធាវីបានឡើយ[45]។ ការឆែកឆេរអាចធ្វើបានដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរហើយការឆែកឆេរនេះត្រូវធ្វើនៅចំពោះមុខ ប្រធានគណៈមេធាវីដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចបំពានបាន

44. កំណត់ហេតុស្តីពីការឆែកឆេរ របស់មន្ត្រីនគរបាលយុត្តិធម៌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ មាននៅ ក្នុងឧបសម្ព័ន្ធ

45. យោងតាមប្រសាសន៍ ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលបេសកកម្ម មន្ត្រីនគរបាលយុត្តិធម៌ ថ្ងៃទី២០ ដល់២៤ ខែមិថុនា ឆ្នាំ២០១៦

ឡើយហើយម្យ៉ាងវិញទៀត គឺដល់វិជ្ជាជីវៈសារព័ត៌មាន ព្រោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើងក៏បានការពារផងដែរ។ ចំពោះវិជ្ជាជីវៈសារព័ត៌មាន ទាំងសារព័ត៌មានសេរសេរ និងសារព័ត៌មានសោតទស្សន៍ គឺមានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងអាគារសារព័ត៌មាន ដោយឯកឯងបានទេគាត់ត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរម្នាក់។ ហេតុអ្វីចាំបាច់មានវត្តមានព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរម្នាក់ នៅពេលធ្វើការឆែកឆេរនៅក្នុងសហគ្រាសទាំងនោះ? ព្រោះគាត់ជាអ្នកធានារ៉ាប់រងកុំឱ្យមានការឆែកឆេរ ក្លាយទៅជាការរំលោភបំពានដែលនាំឱ្យមានការយឺតយ៉ាវក្នុងការប្រកបវិជ្ជាជីវៈដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយាវដល់ការផ្សព្វផ្សាយព័ត៌មាន។ <u>**ជាឧទាហរណ៍**</u> មន្ត្រីនគរបាលយុត្តិធម៌គាត់ឆែកឆេរដោយបំពានដោយសារគាត់ទៅឆែកឆេរការិយាល័យមេធាវី ឬ អគារសារព័ត៌មានដោយឯកឯង។ក្នុងករណីនេះការឆែកឆេរត្រូវចាត់ ទុកជាមោឃៈបានន័យថាអ្វីដែលទទួលបាននៅក្នុងនីតិវិធីនោះគឺមិនអាចយកជាបានការឡើយ[46]។

**១.២.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង**

បើសិននៅក្របខណ្ឌនៃការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌បានរកឃើញនូវវត្ថុណាមួយដែលគួរឱ្យសង្ស័យគាត់មានសិទ្ធិអំណាចចាប់យកវត្ថុតាងនោះបាន។ ពាក្យនេះជាពាក្យថ្មីដែលប្រើក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើងពាក្យថា**ចាប់យកវត្ថុតាង** ដែលពីមុនតែងឮថា **ការរឹបអូស**[47]។ ឥឡូវនេះបានន័យថា គាត់ចាប់ផ្តើមប្រតិបត្តិការនៃការឆែកឆេរក៏បានរកឃើញវត្ថុតាងផ្សេងៗ ទាក់ទងនឹងបទល្មើសគាត់អាចចាប់យកវត្ថុតាងនោះបាន ក្រោយពេលដែលគាត់ចាប់យកវត្ថុតាង នោះមកហើយ គាត់ត្រូវវេចខ្ចប់ភស្តុតាងនេះទុក។ ជាទូទៅបើមើលឱ្យបានលម្អិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌគឺមានលក្ខណៈបច្ចេកទេសខ្លាំងណាស់មានន័យថា គាត់ត្រូវបង្ហាញសាក្សី០២នាក់ ឬ អ្នកកាន់កាប់ទីកន្លែងថា គាត់ចាប់បាន ភស្តុតាងនេះ ហើយគាត់បានចាប់យកទៅវេចខ្ចប់ ពេលដែលវេចខ្ចប់ហើយមានបិទស្លាក និងបោះត្រា ដើម្បីរក្សាទុកមិនមានការលួចដូរនោះឡើយ។ មិនត្រឹមតែប៉ុណ្ណោះនៅពេលដែលគាត់បញ្ចប់ប្រតិបត្តិការណ៍ របស់ខ្លួនគាត់ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃវត្ថុតាងទាំងឡាយដែលបានចាប់យកហើយត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយទៀត កំណត់ហេតុនៃការឆែកឆេរត្រូវកំណត់ឱ្យបានច្បាស់អំពីការអនុញ្ញាតនៅ វេលាម៉ោងដែលព្រះរាជអាជ្ញាគាត់ផ្តល់ការអនុញ្ញាតឱ្យហើយការអនុញ្ញាតនោះអាចជាលាយលក្ខខអក្សរ ឬ ដោយផ្ទាល់មាត់។ កំណត់

46. យោងតាមប្រសាសន៍ ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិ វិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

47. យោងតាមប្រសាសន៍ ឯកឧត្តម ជូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ហេតុនេះត្រូវចុះហត្ថលេខាដោយអ្នកចូលរួមមានន័យថា សំដៅជាពិសេសទៅដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សី២ (ពីរ) រូបដែលមានវត្តមានហើយដាច់ខាតត្រូវតែមានគាត់ចុះហត្ថលេខា ឬ ផ្តិតម្រាមដៃ។

**១.២.៤ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ**

ប្រសិនបើត្រូវការ ធ្វើការពិនិត្យបច្ចេកទេស ឬ វិទ្យាសាស្ត្រដែលមិនអាចបង្អង់បានមន្ត្រីនគរបាលយុត្តិធម៌ អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញឱ្យធ្វើការពិនិត្យផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រទៅលើភស្តុតាងដែលគាត់ទទួលបាននោះ ដើម្បីឱ្យគាត់អាចតាមស្វែងរកភស្តុតាបន្តទៀត។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះ បុគ្គលនេះត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួន ថានឹងជួយដោយភក្តីភាពដល់តុលាការ[48]។

**១.២.៥ ការស្តាប់ចម្លើយ និងបងបញ្ជាឱ្យចូលខ្លួន**[49]

តើនគរបាលយុត្តិធម៌មានវិធីសាស្ត្របែបណាខ្លះនៅក្នុងការស្តាប់ចម្លើយ? នៅក្នុងក្របខណ្ឌនៃការស្តាប់ចម្លើយក្រមនីតិវិធីព្រហ្មទណ្ឌយើងពុំបានបែងចែកពាក្យថា អំណាចឱ្យខុសគ្នានោះទេ ព្រោះជាគោលការណ៍គឺមានអំណាចដូចគ្នា។ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងត្រង់មាត្រា ៩៣ និងមាត្រា៩៤ បានកំណត់យកនូវគោលការណ៍ ២ ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការងារទាក់ទងជាមួយការស្តាប់ចម្លើយ។

ទីមួយ គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅបុគ្គលគ្រប់រូប រួមទាំងជនដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ដើម្បីផ្តល់ព័ត៌មាននឹងដកស្រង់យកចម្លើយ។ ដូច្នេះគ្រប់ការស្តាប់ចម្លើយត្រូវតែមានកំណត់ហេតុ ហើយកំណត់ហេតុនេះត្រូវបញ្ជាក់នូវព័ត៌មានមួយចំនួនមានន័យថាជាព័ត៌មានដែលចាំបាច់សំខាន់ៗ ដើម្បីឱ្យអាជ្ញាធរតុលាការ ជាពិសេសខាងព្រះរាជអាជ្ញា និងចៅក្រមពិនិត្យពី នីត្យានុកូលភាព និងនិយ័តភាពនៃការស្តាប់ចម្លើយនេះ។ ការធ្វើកំណត់ហេតុ នេះ ត្រូវបញ្ជាក់ពីធាតុពិត ឬ ការពិត នៃការឆ្លើយរបស់ជនដែលពាក់ព័ន្ធហើយនៅគ្រប់កំណត់ហេតុនីមួយៗ ត្រូវមានចុះហត្ថលេខា ឬ ផ្តិតម្រាមដៃរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាជនដែលពាក់ព័ន្ធ ឬ អ្នកដែលត្រូវបានស្តាប់ចម្លើយ។ មុននឹងចុះហត្ថលេខា ឬ ផ្តិតម្រាមដៃបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវ អានដោយសម្លេង

48. មាត្រា៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

49. យោងតាមប្រសាសន៍ ឯកឧត្តម ជូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬ មិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធមិត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុដូចសរសេរថា "បានអានឱ្យស្តាប់រួចហើយ តែបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬ មិនព្រមផ្តិតម្រាមដៃទេ។ ម្យ៉ាងទៀតរាល់កំណត់ហេតុទាំងឡាយណាដែលមានកាឆូតលុប ក៏ត្រូវមានការចារ និងឯកភាពគ្នាដែរ។ បើក្នុងករណីអ្នកដែលបានកោះហៅមកមិនចេះភាសាខ្មែរនោះ មន្ត្រីនគរបាលយុត្តិធមិ អាចរកអ្នកបកប្រែដែលបានស្បថទៅតាមប្រពៃណី សាសនា និងជំនឿរបស់ខ្លួន។

ទីពីរ គ្រប់ការស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធមិមានសិទ្ធិកោះហៅ ជនដែលមានផលប្រយោជន៍ដើម្បីមកបំភ្លឺ ឬ ផ្តល់ព័ត៌មាន។ ក្នុងករណីដែលជននោះរឹងទទឹងដោយមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធមិមានសិទ្ធិស្នើសុំទៅព្រះរាជអាជ្ញាដើម្បីសុំឱ្យចេញបញ្ជាឱ្យចូលខ្លួន ព្រោះបញ្ជាឱ្យចូលខ្លួននេះ គឺផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធមិឱ្យកេណ្ឌកម្លាំងសាធារណៈដែលចាំបាច់ចាប់ខ្លួនជននេះមកបំភ្លឺនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធមិ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។ ដូច្នេះ កិច្ចទាំងឡាយណាដែលមិនគោរពនូវវិធានដូចដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះនឹងនាំឱ្យមាន មោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធមិក្នុងការស្តាប់ចម្លើយ យោងតាមមាត្រា១០៩ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧។

<u>**ឧទាហរណ៍**</u> ក្នុងករណីស្តាប់ចម្លើយ ធ្វើឡើងដោយសារតែមានលក្ខណៈមិនប្រក្រតី ឬ ការគៀបសង្កត់គ្រង់សកម្មភាពណាមួយមកទៅលើជនដែលត្រូវបានសួរចម្លើយ។ ក្រៅពីនេះនៅមានគោលការណ៍លម្អិតមួយទៀតចំពោះមន្ត្រីនគរបាលយុត្តិធមិគឺនៅពេលដែលកោះហៅជនសង្ស័យ ឬជនដែលពាក់ព័ន្ធមកសួរចម្លើយ គឺមិនត្រូវពន្យាពេលសួរចម្លើយដើម្បីគៀបសង្កត់ផ្នែកចិត្តសាស្ត្រជននោះឡើយក្នុងករណីប្រសិនបើតុលាការរកឃើញនូវ ចំណុចមិនប្រក្រតីទាំងនេះនីតិវិធីកំណត់ហេតុសួរចម្លើយនឹងត្រូវមោឃភាព។ ជាគោលការណ៍នៅពេលកោះហៅជនសង្ស័យ ឬ ជនដែលពាក់ព័ន្ធត្រូវតែសួរចម្លើយភ្លាម គឺមិនត្រូវចាំបាច់ថា កោះហៅមកពេលព្រឹកព្រលឹម សួរពេលល្ងាចឡើយ ព្រោះនេះគេហៅថាជាការគៀបសង្កត់ចិត្តសាស្ត្រមួយ នាំឱ្យមានភាពមិនប្រក្រតី នៅក្នុងការសួរចម្លើយ។ ហើយនៅក្នុងរយៈពេលសួរចម្លើយគឺគោលការណ៍ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធមិ គឺពុំមានសិទ្ធិស្តាប់ចម្លើយជនដែលពាក់ព័ន្ធនោះទេ មានតែអ្នកដែលមានគុណភាពជាមន្ត្រីនគរបាលយុត្តិធមិតាមការកំណត់របស់ក្រមនីតិវិធីព្រហ្មទណ្ឌ បានមានសិទ្ធិស្តាប់ចម្លើយ។ ជាគោលការណ៍គឺរយៈពេល ៣០នាទី ទៅ៤៥នាទី ត្រូវមានការឈប់សម្រាកម្តងដើម្បីកុំឱ្យថាសួរពង្វក់បែបចិត្តសាស្ត្រ

ធ្វើឱ្យគ្នាឡប់អ្នកដែលពាក់ព័ន្ធឆ្លើយទៅអត់បានផលប្រយោជន៍[50]។

**១.៣ ការឃាត់ខ្លួន** [51]

យើងពិនិត្យឃើញថា កាឃាត់ខ្លួននៅក្នុងការស៊ើបអង្កេតក្នុងករណីជាក់ស្តែងមានចែងពីមាត្រា៩៦ដល់មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះធ្វើការឃាត់ខ្លួនជនណាម្នាក់ត្រូវតាមនីតិវិធីអ្វីខ្លះ? ហើយត្រូវគោរពបទដ្ឋានកម្រិតណាចំពោះការឃាត់ខ្លួន? យើងខ្ញុំនឹងលើកយកមកពិភាក្សានៅចំណុចនីមួយៗដូចតទៅ ៖

**១.៣.១ លក្ខខ័ណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់ខ្លួន**

យោងតាមមាត្រា៩៦ នៃក្រមនេះបានចែងថា "ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធមិអាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួម ក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធមិក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានអំពី រឿងហេតុបានដែរប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន និង មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ យើងត្រូវពិនិត្យមើលថាការឃាត់ខ្លួនត្រូវគោរពលើលក្ខខ័ណ្ឌ ០២ (ពីរ) ៖

ចំពោះការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសពេលនេះការឃាត់ខ្លួនត្រូវបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា។ ប៉ុន្តែចំពោះបុគ្គលមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធមិចង់បានព័ត៌មានពីគាត់ដែលជួនកាលគាត់មិនបានប្រព្រឹត្តបទល្មើសទេ តែគាត់អាចធ្វើជាសាក្សីដែល មន្ត្រីនគរបាលយុត្តិធមិចង់បានព័ត៌មានពីគាត់បែរជាគាត់បានបដិសេធមិនព្រមផ្តល់ព័ត៌មានឡើយ។ ហេតុនេះ បានចូលទៅក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា៩៦ ហើយ ព្រោះទីមួយគាត់ប្រកែកមិនព្រមផ្តល់ព័ត៌មាន និង ទីពីរ មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីព្រះរាជអាជ្ញា ដូច្នេះទើបមន្ត្រីនគរបាលយុត្តិធមិអាចឃាត់ខ្លួនបុគ្គលនោះបាន។

**១.៣.២ រយៈពេលនៃការឃាត់ខ្លួន**

ទាក់ទងនឹងរយៈពេលនៃការឃាត់ខ្លួន គឺមានថេរវេលាតែ៤៨ ម៉ោងប៉ុណ្ណោះ ព្រោះនេះជាពេលវេលាមួយដែលច្បាប់អនុញ្ញាត តែចំពោះបទឧក្រិដ្ឋ ហើយមើលទៅឃើញថាបុគ្គលដែលបានឃាត់ខ្លួននោះមានតម្រុយច្រើនបង្ហាញថា បុគ្គលនេះអាចពាក់ព័ន្ធនឹងបទឧក្រិដ្ឋ។ រយៈពេលនេះអាចសុំពន្យាបាន ២៤ម៉ោងទៀត។ ហើយការពន្យាពេលមិនអាចលើសពី ២៤ម៉ោង បានទេ និងត្រូវ

50. យោងតាមប្រសាសន៍ ឯកឧត្តម ផូវ សំភី អគ្គនាយកស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

51. យោងតាមប្រសាសន៍របស់ ឯកឧត្តម ប៊ិន ហុន អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សុំការអនុញ្ញាតពីព្រះរាជអាជ្ញាថែមទៀតផង។ នៅពេលដែលមានសុំការអនុញ្ញាតនេះ ព្រះរាជអាជ្ញាគាត់នឹងផ្ទៀងផ្ទាត់មើលថា តើការសុំពន្យាពេលរបស់មន្ត្រីនគរបាលយុត្តិធម៌មានមូលហេតុសមហេតុផលដែរ ឬ ទេ ? ដែលក្នុងច្បាប់យើងនេះគេហៅថាពិនិត្យមើលមូលកភាព មានន័យថាមើលទៅមានលក្ខណៈសមស្របដែរ ឬ ទេ ? នេះជាចំណុចសំខាន់ មិនមែនចេះតែសុំពន្យាពេលចង់ទុកគេឱ្យនៅយូរនោះទេសំខាន់ទាល់តែមន្ត្រីនគរបាលយុត្តិធម៌មានតម្រុយបញ្ជាក់ថាបុគ្គលនោះ មានពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសដែរ ទើបគាត់អាចសុំពន្យាពេលដើម្បីយកចម្លើយបន្ថែម ឬ ចង់បានការស្វែងរកភស្តុតាងផ្សេងៗទៀតរបស់ខ្លួន។ ហើយចំពោះការឃាត់ខ្លួននេះមានលក្ខណៈខុសៗគ្នាចំពោះបុគ្គលដែលត្រូវឃាត់ខ្លួន។ បើមនុស្សពេញវ័យ គឺចាប់ពីអាយុ១៨ឆ្នាំ ឡើងទៅការឃាត់ខ្លួនត្រូវមាន រយៈពេល ៤៨ម៉ោង ហើយបទឧក្រិដ្ឋក្នុងករណីមានតម្រុយបញ្ជាក់ថាមានពិរុទ្ធភាពចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលបាន ២៤ម៉ោង ការសុំពន្យារពេលឃាត់ខ្លួនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានសម្អឹងហេតុត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យារគឺជាវិធានការពិសេស ផ្ទុយទៅវិញចំពោះអនីតិជនមិនអាចធ្វើបែបនេះបានទេ មានន័យថាការពន្យារពេលមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។

### ១.៣.៣. ការឃាត់ខ្លួនចំពោះអនីតិជន

ការឃាត់ខ្លួនចំពោះអនីតិជនយើងត្រូវធ្វើការញែកចេញអនីតិជនជា៣ (បី) ប្រភេទគឺ កំណត់ទៅតាមអាយុរបស់អនីតិជនដែលត្រូវធ្វើការឃាត់ខ្លួន ប្រភេទ ទី១ អាយុក្រោម១៤ឆ្នាំ ប្រភេទទី២ អាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ និងប្រភេទទី៣ អាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បញ្ជាក់ចំពោះអនីតិជនអាយុក្រោម១៤ឆ្នាំ មិនអាចឃាត់ខ្លួនបានឡើយ។

ចំពោះអនីតិជនដែលមានអាយុពី១៤ឆ្នាំ ដល់ក្រោម១៦ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មិនអាចត្រូវឃាត់ខ្លួនឱ្យហួសរយៈពេល ៣៦ម៉ោង ឡើយ។

ចំពោះអនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋមិនអាចត្រូវឃាត់ខ្លួនឱ្យហួសរយៈពេល ៤៨ម៉ោង ឡើយ។

ចំពោះអនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនឱ្យហួសរយៈពេល ២៤ម៉ោង ឡើយ។

ចំពោះអនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ដែលត្រូវបានចោទ ប្រកាន់ពីបទមជ្ឈិម មិនអាចត្រូវឃាត់ខ្លួនឱ្យហួសរយៈពេល ៣៦ម៉ោង ឡើយ។

ចំណុចមួយទៀត ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំពោះការឃាត់ខ្លួនអនីតិជននោះ គឺកាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជនមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់

មធ្យោ បាយដល់ ឪពុក-ម្តាយ អ្នកតំណាងស្របច្បាប់ ឬ ដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ[52]។

**១.៣.៤ កំណត់ហេតុស្តីពីការឃាត់ខ្លួន**

នីតិវិធីនេះមានចែងក្នុងមាត្រា ៩៧ នៃក្រមនេះ គឺការឃាត់ខ្លួនត្រូវតែធ្វើកំណត់ហេតុព្រោះមិនមែនចេះតែឃាត់ខ្លួនគេដោយមិនបានធ្វើកំណត់ហេតុនោះទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលដែលត្រូវបានឃាត់ខ្លួន ដើម្បីឱ្យគាត់បានដឹងពីមូលហេតុដែលនាំឱ្យមានការឃាត់ខ្លួនគាត់ និងត្រូវប្រាប់ឱ្យសាមីខ្លួនបានដឹងថាគាត់មានសិទ្ធិពឹងពាក់មេធាវីដើម្បីការពារខ្លួនដែលនេះជាប្រការមួយដើម្បីជៀសវាងនូវការរំលោភសិទ្ធិ និងផលប្រយោជន៍ពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពានទៅលើច្បាប់ និងបំពានទៅលើប្រជាជនដែលមិនសូវចេះច្បាប់។ ក្នុងករណីចាំបាច់ការយកចម្លើយផ្សេងៗបើជនដែលត្រូវបានឃាត់ខ្លួនជាជនបរទេសដែលគាត់មិនអាចស្តាប់យល់ភាសាខ្មែរបាននោះ ដូច្នេះគាត់មានសិទ្ធិសុំឱ្យមានអ្នកបកប្រែភាសាដើម្បីឱ្យនិយាយស្តាប់គ្នាបាន អ្នកបកប្រែភាសានោះមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការឡើយ។ តើកំណត់ហេតុឃាត់ខ្លួនត្រូវចុះនិទ្ទេសអ្វីខ្លះ? មន្ត្រី នគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុឃាត់ខ្លួន[53] ជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន
- អត្តសញ្ញាណ នៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុ នៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨[54] នៃក្រមនេះជាយថាហេតុ ឈ្មោះអ្នកបកប្រែ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬ ផ្តិតស្រាមដៃរបស់ជនឃាត់ខ្លួនក្រោយពីបានអានកំណត់ហេតុរួច ឬ បើសាមីខ្លួនមិនចេះអក្សរមន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាយប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬ ផ្តិតស្រាមដៃនោះទេមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេស[55]។ ហើយកំណត់ហេតុនេះត្រូវភ្ជាប់ទៅជាមួយនឹងសំណុំរឿងនេះផង។

52. មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
53. កំណត់ហេតុឃាត់ខ្លួន របស់មន្ត្រីនគរបាលយុត្តិធម៌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ មាននៅក្នុងឧបសម្ព័ន្ធ
54. បញ្ញាត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧
55. អត្ថន័យចុះនិទ្ទេស "បានអានឱ្យស្តាប់រួចរាល់ហើយតែបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬ មិនផ្តិតស្រាមដៃ

**<u>សូមបញ្ជាក់</u>** : ពាក្យថាផ្តិតម្រាមដៃ ហេតុអ្វីបានជាក្រមនេះបានចែងថា ជនដែលត្រូវឃាត់ខ្លួនផ្តិតម្រាមដៃហេតុអ្វីមិនចែងថាផ្តិតមេដៃ? ព្រោះហេតុថាពេលខ្លះជនដែលត្រូវឃាត់ខ្លួននោះ អត់មានមេដៃដោយសារតែគាត់ពិការមេដៃតាំងពីកំណើត ឬ ពិការដោយឧប្បត្តិហេតុណាមួយ ឬ ក៏ជននោះកាត់មេដៃខ្លួនឯងទាំងសងខាងដើម្បីបំផ្លាញអត្តសញ្ញាណផ្ទាល់ខ្លួន ដូច្នេះគាត់មានតែម្រាមដៃតើឱ្យគាត់ផ្តិតមេដៃម្តេចនឹងកើត?នេះហើយគឺជាគោលការណ៍ដែលបើកទូលាយក្នុងការអនុវត្តនីតិវិធី។

### ១.៣.៥ ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ពាក់ព័ន្ធនឹងការឃាត់ខ្លួននេះដែរ បើសិនជាគាត់ចង់រកជំនួយពីសំណាក់មេធាវី គឺមិនមែនរកភ្លាមបានភ្លាមនោះទេនៅក្នុងមាត្រា៩៨ នៃក្រមនេះអនុញ្ញាតឱ្យគាត់រកមេធាវីបាន កាលណារយៈពេល ២៤ម៉ោងបានកន្លងហួសទៅក្រោយពីការឃាត់ខ្លួនគាត់អាចទាក់ទងជាមួយមេធាវី ឬ អ្នកណាផ្សេងដែលមិនមានទំនាក់ទំនងជាមួយអំពើល្មើស ដើម្បីពិភាក្សាជាមួយគ្នាបានចំនួន ៣០ នាទីតែប៉ុណ្ណោះ។ នៅពេលដែលធ្វើការសន្ទនាគ្នា គឺត្រូវធ្វើនៅក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់ នៃការសន្ទនាមានន័យថាមិនឱ្យមន្ត្រីនគរបាលយុត្តិធម៌ ឬ អ្នកដទៃផ្សេងទៀត ទៅលួចស្តាប់ការសន្ទនាថា តើពួកគេនិយាយគ្នាពីអ្វីនោះបានឡើយ។ ក្រោយការសន្ទនារួចហើយ ជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ ជាពិសេសមេធាវី ឬ ជនណាម្នាក់ ដែលមិនមានទាក់ទិននៅក្នុងរឿងជាមួយជនត្រូវឃាត់ខ្លួននោះ បានជ្រើសរើសឱ្យមកធ្វើជាជំនួយរបស់ខ្លួនត្រូវតែបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះតាមគ្រប់មធ្យោបាយ និងជាបន្ទាន់ហើយអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន។

### ១.៣.៦ ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ប្រសិនបើមានការចាំបាច់ដើម្បីពិនិត្យសុខភាពនោះមន្ត្រីនគរបាលយុត្តិធម៌អាចសុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា។ គ្រូពេទ្យត្រូវផ្ទៀងផ្ទាតមើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះសមស្របនឹងការឃាត់ខ្លួនដែរ ឬ ទេ? បើសិនជាគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះមន្ត្រីនគរ បាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យត្រូវចេញវិញ្ញាបនប័ត្រ បញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។ រីឯមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅលើកំណត់ ហេតុអំពីឈ្មោះរបស់គ្រូពេទ្យនោះព្រមទាំងថ្ងៃ-ខែ-ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព។ ប្រសិនបើព្រះរាជអាជ្ញាចង់ផ្ទៀងផ្ទាត់មើលលក្ខខណ្ឌនៃការឃាត់ខ្លួននេះ គាត់អាចចុះទៅកាន់កន្លែងនោះផ្ទាល់ ដើម្បីធ្វើការនេះបាន[56]។

56. មាត្រា៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ១.៣.៧ បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងអង្គភាពនីមួយៗរបស់កងរាជអាវុធហត្ថ ឬ នគរបាលគឺសំដៅទៅលើមន្ត្រីនគរបាលយុត្តិធម៌សម្រាប់ទទួលជនដែលត្រូវបានឃាត់ខ្លួនត្រូវតែមានបញ្ជីស្តីពី ការឃាត់ខ្លួនមួយដើម្បីធានាថាគ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីនេះ។

បញ្ជីស្តីពីការឃាត់ខ្លួនមានសេចក្តីដូចតទៅ ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ
- ឈ្មោះ របស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[57]។

### ១.៣.៨ កំណត់ហេតុសរុបនៃការឃាត់ខ្លួន

ហេតុអ្វីបានជាគេបង្កើតឱ្យមានកំណត់ហេតុសរុបនៃការឃាត់ខ្លួនមួយនេះ? ព្រោះដើម្បីឱ្យគ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុប នៃការឃាត់ខ្លួន។ កំណត់ហេតុមួយនេះត្រូវមានចុះនិទ្ទេសដូចតទៅ ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ-ខែ-ឆ្នាំ និងម៉ោងដែលផ្តើមការឃាត់ខ្លួន
- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបាន សន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

57. មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន
- ចិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងចិរវេលានៃការសម្រាក់ដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ
- ថ្ងៃ-ខែ-ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួនព្រមទាំង ឧប្បត្តិវហេតុជាយថាហេតុ
- កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង[58]។

### ១.៤ ការបញ្ជូនខ្លួន

យើងបានដឹងហើយថារយៈពេលនៃការឃាត់ខ្លួនគឺអាចឈានទៅដល់៤៨ ម៉ោងទោះបីរយៈពេលដែលច្បាប់អនុញ្ញាតជាអតិប្បរមាគឺ ៤៨ ម៉ោងហើយបើបទឧក្រិដ្ឋដែលយល់ឃើញ ថាមានតម្រុយអាចពន្យាបាន ២៤ ម៉ោង នេះគ្រាន់តែជារយៈពេលអតិប្បរមា មិនមែនកំណត់ថា ទាល់តែផុត ៤៨ ម៉ោង បានបញ្ជូនខ្លួនគេទៅតុលាការនោះទេ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់តែ ៥ ម៉ោង ឬតិចជាងនេះ គាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរព្រោះនៅពេលដែលផុតរយៈពេលនេះគាត់ត្រូវតែបញ្ជូនបុគ្គលដែលឃាត់ខ្លួននោះទៅព្រះរាជអាជ្ញាតែម្តង។ ដូច្នេះមិនមែនមានន័យថាឱ្យតែគ្រប់ការឃាត់ខ្លួន ទាល់តែគ្រប់រយៈពេលនេះចាំបញ្ជូនគេទៅនោះទេ។ ដោយមូលហេតុនេះហើយទើបពាក់ព័ន្ធនឹងការបញ្ជូនខ្លួននេះ យើងត្រូវពិនិត្យនូវ ២ (ពីរ) ចំណុចដូចខាងក្រោម ៖

#### ១.៤.១ ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញាហើយបើគាត់មើលឃើញថាវាមិនមានអ្វីធ្ងន់ធ្ងរទេព្រះរាជអាជ្ញា អាចមិនបញ្ជូនខ្លួនជននោះទៅឱ្យចៅក្រមស៊ើបសួរទៀតទេគាត់អាចបន្តនីតិវិធីរបស់គាត់ ប៉ុន្តែដោះលែងបុគ្គលនោះឱ្យត្រឡប់មកផ្ទះដើម្បីមានសេរីភាពដូចដើមឡើងវិញ។ សេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយព្រះរាជអាជ្ញាមានន័យថាអាចសម្រេចបញ្ជូនទៅចៅក្រមស៊ើបសួរ ឬ ដោះលែងឱ្យមានសេរី ភាពវិញ[59]។

#### ១.៤.២ រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។ ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនពុំអាចធ្វើឡើងនៅ ថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសខ្លះៗដែលបណ្តាលមកពីការ

58. មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
59. មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

លំបាកក្នុងការដឹកជញ្ជូនដូចជា ឡានបែកកង់ ឡានអស់សាំង ឬ ចម្ងាយផ្លូវនៃការដឹងជញ្ជូន នោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។ នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ នូវមូលហេតុនៃការយឺតយ៉ាវ ហើយត្រូវប្រគល់ជូនព្រះរាជអាជ្ញា[60]។

### ១.៥ វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

វិធានទាំងនេះមានចែងចាប់ពីមាត្រា១០៥ ដល់មាត្រា១១០ នៃក្រមនេះ ដូច្នេះយើងខ្ញុំសុំធ្វើការពន្យល់ដូចខាងក្រោមដែលមាន ៤ (បួន) ចំណុចតូចៗ ដូចតទៅ ៖

#### ១.៥.១ ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ការស៊ើបអង្កេតបទល្មើសជាក់ស្តែងមានថិរវេលាមិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃបានឡើយ គិតពីថ្ងៃប្រព្រឹត្តបទល្មើស មានន័យថាកិច្ចស៊ើបអង្កេតត្រូវតែប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលា ៧ (ប្រាំពីរ) ថ្ងៃ នេះហើយ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ថាតើគួរធ្វើបែបណាទៀតចំពោះសំណុំរឿងនេះ[61]? ពេលនោះព្រះរាជអាជ្ញាគាត់នឹងឆ្លើយតប ថាគួរធ្វើបែបណាជាក់ជាមិនខានឡើយ ដោយពឹងផ្អែកទៅលើស្ថានភាពជាក់ស្តែង។

#### ១.៥.២ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា និងនិទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុនោះ

ក្រោយពីការបិទបញ្ចប់នៃការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ បើបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះផងដែរ[62]។ កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេសដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនោះ
- កាលបរិច្ឆេទ។

60. មាត្រា១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
61. មាត្រា១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
62. មាត្រា១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬ ស្តីពីការឃាត់ខ្លួនត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធហើយទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌។ ប្រសិនបើមានពាក្យណាត្រូវបានឆូតលុប និងការយោងត្រូវមានបញ្ជាក់ថាបានយល់ព្រមដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាយុត្តិធម៌នៅរឹមទំព័រ[63]។

**ឧទាហរណ៍** ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុដោយមានការ ភ័ន្តច្រឡំឈ្មោះ **វី** លុបចេញ រួចកែដាក់ឈ្មោះ **ពី** វិញ ដោយមានការយល់ព្រមពីជនសង្ស័យ ឬ បុគ្គលដែលជាប់ពាក់ព័ន្ធប្រព្រឹត្តបទល្មើស។ យោងតាមមាត្រា១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពី អំណាចមូលវិចារណ៍របស់ចៅក្រម គឺបានបញ្ញាតថា ជាគោលការណ៍កំណត់ហេតុនេះ មានតម្លៃគ្រាន់តែជាព័ត៌មានធម្មតាប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ (ឯកសារដើម) មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿទុកចិត្តបំផុត រហូតដល់មានភស្តុតាងផ្ទុយ។ ហើយចំពោះភស្តុតាងផ្ទុយនេះអាចបញ្ជូនមកចៅក្រមបានដោយសេរីតាម គ្រប់មធ្យោបាយត្រឹមត្រូវតាមផ្លូវច្បាប់។ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងចៅក្រមធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌។

### ១.៥.៣. ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍

នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតករណីជាក់ស្តែងនេះ មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ ឬក៏សារតាមអិនធើណែត។ នេះបើយោងតាមមាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពី (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍)។ បើយើងក្រលេកមកមើយមាត្រា១៨៣ នៃក្រមនេះដដែលវិញ គេបានចែងពីការផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ កាលណា ដីកាចាត់ឱ្យស៊ើបសួរបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរសារ ឬ សារតាមអិនធើណែតមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់អំណាចដែលប្រគល់ឱ្យពីចៅក្រមស៊ើបសួរ ដោយវាក្យខណ្ឌទី២ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ ដែលបង្គាប់ដោយ ចៅក្រមស៊ើបសួរ)នៃក្រមនេះ។

### ១.៥.៤. មោឃភាព នៃការមិនគោរពវិធានបញ្ញត្តិ

ត្រង់ចំណុចមោឃភាព នៃការមិនគោរពវិធានបញ្ញត្តិនេះយើងឃើញថានៅក្នុងម្រាតា១០៩

63. មាត្រា ១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

នៃក្រមនីតិវិធីព្រហ្មទណ្ឌ យើងមានវិធាន និងទម្រង់ដែលបានបញ្ញត្តិនៅមាត្រាមួយចំនួន ដូចទៅ ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩១ (ការឆែកឆេរ)
- មាត្រា ៩២ (ការបិទស្លាកលើវត្ថុតាង)
- មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)
- មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង)
- និងមាត្រា ១០៨(និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ។

មានលក្ខណៈដាច់ខាតត្រូវតែគោរពបើមិនដូច្នេះទេ នឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។

## កថាខណ្ឌទី២ ការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែង

ក្រៅពីការស៊ើអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីបទល្មើសជាក់ស្តែងពួកគាត់ក៏អាចធ្វើការស៊ើអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែងបានដែរ ដោយគ្រាន់តែត្រូវគោរព នូវនីតិវិធីមួយចំនួនដូចទៅ៖

### ២.១ អត្ថន័យបទល្មើសមិនជាក់ស្តែង

គឺចង់សំដៅថា នៅក្នុងករណីនៃការស៊ើបអង្កេតបឋម ឬ ការស៊ើបអង្កេតក្នុងករណី មិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តន៍ទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា១១១ ដល់មាត្រា១១៨។

**ចំណាំ** អំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្តែង គឺធំជាងអំណាចក្នុងការស៊ើបអង្កេតករណីមិនជាក់ស្តែង។ អំណាចនៅក្នុងករណីស៊ើបអង្កេតបឋមនេះដែលគេហៅថាករណីមិនជាក់ស្តែង គឺខុសពីអំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្តែង ដែលខ្ញុំនឹងលើកយកមកបង្ហាញដូចខាងក្រោម ៖

### ២.១.១. ការបើកការស៊ើបអង្កេតបឋម

ទាក់ទងនឹងការបើកស៊ើបអង្កេតបឋមមានភាពខុសគ្នាទៅនិងការបើកការស៊ើបអង្កេតករណីជាក់ស្តែងដូចមានចែងក្នុងមាត្រា១១១ ថា "កាលណាបានដឹងពីអំពើដែលអាចជាបទ ឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា"។

<u>បញ្ជាក់</u> ក្នុងការអនុវត្តន៍ជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌ ចំពោះការបើកការស៊ើបអង្កេតបឋមនេះ ត្រូវធ្វើពាក្យស្នើសុំបើកការស៊ើបអង្កេតបឋម[64] ពីព្រះរាជអាជ្ញាជាមុនសិន ដើម្បីបន្តអនុវត្តន៍តាមនីតិវិធី។ ក្នុងករណីព្រះរាជអាជ្ញាមិនអនុញ្ញាត គាត់ត្រូវចុះនិទ្ទេសថា "មិនអនុញ្ញាតលើសំណើសុំគប្បី មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងមកអយ្យការ ដើម្បីចាត់ការតាមនីតិវិធី[65]។ រីឯករណីដែលព្រះរាជអាជ្ញាអនុញ្ញាតគាត់ត្រូវចុះនិទ្ទេសថា "អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតបឋមតាមការស្នើសុំ (អនុវត្តតាមមាត្រា ៣៧[66] ៧៥[67] និង១១១[68] នៃក្រមនីតិវិធីព្រហ្មទណ្ឌ[69]។ ក្រោយពីទទួលបានការអនុញ្ញាត ក្នុងការលើកបើក ស៊ើបអង្កេតបឋមតាមការស្នើសុំហើយនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចាត់ការបន្តនីតិវិធីភ្លាម ដោយធ្វើការកោះហៅជនសង្ស័យ ឬ បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ឱ្យចូលមកកាន់ការិយាល័យជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការសាកសួរអំពីរឿងហេតុ។ បើសិនជនជនសង្ស័យ ឬ បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសមិនព្រមចូលមកបំភ្លឺ អំពីរឿងហេតុនោះទេមន្ត្រីនគរបាលយុត្តិធម៌នឹងបន្តនីតិវិធី គឺធ្វើសំណើសុំដីកាបញ្ជាឱ្យចូលខ្លួន។ នៅក្នុងនីតិវិធីស្នើសុំដីកាបញ្ជាឱ្យចូលខ្លួននេះយើងខ្ញុំសុំធ្វើការបង្ហាញជូននៅមេរៀនបន្តបន្ទាប់ទៀត ដែលស្តីអំពីដីការបញ្ជាឱ្យចូលខ្លួន។

### ២.១.២ វិធាននដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បើយើងសិក្សាមើលទៅគឺថា ចំពោះវិធានដែលត្រូវអនុវត្តនៅក្នុងករណីស៊ើបអង្កេត បឋមយើងសង្កេតឃើញថាមិនសូវជាខុសគ្នាប៉ុន្មានទេ ទាក់ទងទៅនឹងការស៊ើបអង្កេតករណីជាក់ ស្តែងព្រោះមានមាត្រា ១១២ នៃក្រមនេះ បានបញ្ជាក់ថាបទប្បញ្ញត្តិនៃមាត្រាមួយចំនួន ដែលមាន ចែងនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេត បឋមដែរ។

64. ពាក្យស្នើសុំបើកការស៊ើបអង្កេតបឋម របស់មន្ត្រីនគរបាលយុត្តិធម៌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ មាននៅក្នុងឧបសម្ព័ន្ធ
65. ពាក្យស្នើសុំបើកការស៊ើបអង្កេតបឋម ករណីតុលាការមិនអនុញ្ញាលើសំណើសុំ របស់មន្ត្រីនគរបាលយុត្តិធម៌ នៃបញ្ជា ការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ មាននៅក្នុងឧបសម្ព័ន្ធ
66. អំណាចរបស់ព្រះរាជអាជ្ញា
67. ជម្រើសនៃការចោទប្រកាន់
68. ការបើកការស៊ើបអង្កេតបឋម
69. ពាក្យស្នើសុំបើកការស៊ើបអង្កេតបឋម

ហើយចំពោះមាត្រាទាំងនោះរួមមានដូចខាងក្រោម ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ)

យើងបានដឹងហើយថា ដោយសារតែវិធានការទាំងនេះ យើងបានបកស្រាយយ៉ាងលំអិតរួចមកហើយ នៅក្នុងការស៊ើបអង្កេតករណីជាក់ស្តែងដូច្នេះដើម្បីមានភាពច្បាស់លាស់សូមមេត្តាអាននូវចំនុចដែលពាក់ព័ន្ធនឹងមាត្រាទាំង ៥ នេះដូចមាននៅក្នុងការបកស្រាយខាងលើ។

**២.១.៣ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ**

ដើម្បីកុំឱ្យមានការមោឃភាពនៃនីតិវិធីមន្ត្រីនគរបាលយុត្តិធម៌ គប្បីត្រូវតែគោរពតាមនូវក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រាដូចខាងក្រោម ៖

- មាត្រា៩៦ (ការឃាត់ខ្លួន)
- មាត្រា៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា១១៣ (ការឆែកឆេរ)
- មាត្រា១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនេះ ដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេ នឹងនាំឱ្យមានការមោឃភាពនៃនីតិវិធី[70]។

**២.២ ការឆែកឆេរ**[71]

ការឆែកឆេរនៅក្នុងការស៊ើបអង្កេតបឋម (បទល្មើសមិនជាក់ស្តែង) គឺវាមិនដូចគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែងនោះទេ តែផ្ទុយទៅវិញក៏មានចំណុចមួយចំនួនដូចគ្នាផង ដែរទាក់ទងនឹងបែបបទដែលត្រូវគោរព ដូច្នេះដើម្បីអនុវត្តន៍ឱ្យបានត្រឹមត្រូវ ហើយមានប្រសិទ្ធិភាព ក្នុងការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវគោរពនៅចំណុចមួយចំនួនដូចតទៅ ៖

កាលណាការស៊ើបអង្កេតបឋមនោះបានទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាល

70. មាត្រា១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
71. មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧

យុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបាន។ មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែងដែលការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ តែប្រសិនបើអ្នកកាន់កាប់មិនចេះអក្សរតែសរសេរទេនោះ ឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរហើយយល់ព្រមឱ្យឆែកឆេរ។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬ បដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញ ដីកាអនុញ្ញាតឱ្យឆែកឆេរតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ព្រោះព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវ ការឆែកឆេរនេះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើចំពោះមុខសាក្សី ២ (ពីរ) នាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។

**បញ្ជាក់** សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ការឆែកឆេរមិនអាចផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ។ ក្នុងករណីជាយថាហេតុ ក្នុងការចាប់យកវត្ថុតាង គឺត្រូវយកបទប្បញ្ញត្តិនៃ! មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.៣ ការបញ្ជាឱ្យចូលខ្លួន [72]

ការបញ្ជាឱ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបឋម ត្រូវយកមកអនុវត្តន៍ដូចគ្នានឹងបញ្ជាឱ្យចូលខ្លួនក្នុងករណីនៃការស៊ើបអង្កេតករណីជាក់ស្តែងផងដែរ[73]។ ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា១១៩ ស្តីពីការបញ្ជាឱ្យចូលខ្លួន បានកំណត់យ៉ាងច្បាស់ថា មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ប៉ុន្តែបើសិនក្នុងករណីបុគ្គលនោះ រឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួន តាមការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌នោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជូនដំណឹងដល់ ព្រះរាជអាជ្ញាភ្លាមដើម្បីសុំដីកាបញ្ជាឱ្យចូលខ្លួន ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ[74]។ ហើយការស្នើសុំបញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសឱ្យច្បាស់លាស់បន្ទាប់មកបញ្ជូនពាក្យសុំនោះទៅព្រះរាជអាជ្ញា ពិនិត្យហើយសម្រេច។ នៅ ពេលដែលព្រះរាជអាជ្ញាគាត់អនុញ្ញាត ពេលនោះគាត់នឹងចេញដីកាបញ្ជាឱ្យចូលខ្លួន ដោយមានចុះ ហត្ថលេខារបស់ព្រះរាជអាជ្ញា និងបោះត្រា អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បី

72. មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

73. យោងតាមប្រសាសន៍ ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌ ថ្ងៃ ទី ២០-២៤ ខែមិថុនា ឆ្នាំ២០១៦

74. ពាក្យស្នើសុំដីកាបញ្ជាឱ្យចូលខ្លួន របស់មន្ត្រីនគរបាលយុត្តិធម៌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ នៅក្នុងឧបសម្ព័ន្ធ

បង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបន្តនីតិវិធីស្តាប់ចម្លើយ បុគ្គលដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។

### ២.៤ ការឃាត់ខ្លួនជនសង្ស័យ

ការឃាត់ខ្លួនជនសង្ស័យក្នុងករណីស៊ើបអង្កេតបឋមនេះ យោងតាមមាត្រា១១៦ បានបញ្ញត្តថា "កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ បទប្បញ្ញត្តិ នៃជំពូកទី៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី៤ស្តីពីការបញ្ជូនខ្លួន នៃមាតិកាទី ២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគន្លឹះនេះត្រូវយកមកអនុវត្តដូចគ្នា ការឃាត់ខ្លួនជនសង្ស័យក្នុងករណីមិនជាក់ស្តែងគឺពុំមានអ្វីពិបាក និងជាបញ្ហាអ្វីឡើយ។ ហើយម្យ៉ាងទៀត អត្ថន័យក្នុងការស៊ើបអង្កេតក្នុង ករណីជាក់ស្តែងយើងខ្ញុំបានធ្វើការបកស្រាយយ៉ាងលម្អិតរួចមកហើយគឺយើងមើលឃើញថា ទាក់ទងនឹងការឃាត់ខ្លួនជនសង្ស័យក្នុងករណីអង្កេតបឋម គឺដូចគ្នានឹងការឃាត់ខ្លួនករណីជាក់ស្តែងដែរ។

### ២.៥ កំណត់ហេតុក្នុងការស្តាប់ចម្លើយ

យោងតាមមាត្រា១១៥ នៃក្រមនេះបានបញ្ញត្តិថា ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុហើយកំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាម សាសនា ឬ ជំនឿរបស់ខ្លួនថាខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាលកងរាអាវុធហត្ថ ឬ បុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ"។ ដូច្នេះ រាល់ការស្តាប់ចម្លើយទាំងឡាយដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ចាំបាច់ត្រូវតែគោរពឱ្យបានត្រឹមត្រូវតាមមាត្រា១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពី (កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេត បឋម)។

<u>**ចំណាំ**</u> ក្នុងករណីរកអ្នកបកប្រែគឺសំដៅលើបុគ្គលណាដែលគាត់ស្តាប់ការសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ អំពីភាសាជាតិមិនបាន និងមិនយល់ពីគ្នា (ជនជាតិបរទេស)។

## កថាខណ្ឌទី៣ ការបញ្ចប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលការស៊ើបអង្កេតមួយត្រូវបានធ្វើការសន្និដ្ឋានបញ្ចប់ហើយ នោះអ្នកដែលទទួលខុសត្រូវធ្វើការសន្និដ្ឋាននូវការស៊ើបអង្កេតមាននាទី ធ្វើរបាយការណ៍បញ្ចប់ការស៊ើបអង្កេត។ ការស៊ើបអង្កេតអាចនឹងត្រូវបានបញ្ចប់ ប្រសិនបើល្មើសជនត្រូវបានចាប់ខ្លួន ហើយមានភស្តុតាងគ្រប់គ្រាន់ និងបង្ហាញថាអំពើដែលកើតឡើងនោះ ពិតជាបទល្មើសមួយប្រាកដមែន ហើយពិតជាមានភស្តុតាងគ្រប់គ្រាន់អាចកំណត់បានថា អ្នកដែលប្រព្រឹត្តអំពើនោះ គឺជាជនជាប់ចោទ។ របាយការណ៍នេះ អាចជាការច្របាច់បញ្ចូលដោយមានការសន្និដ្ឋានសរុបនូវរបាយការណ៍ស៊ើបអង្កេតបឋម និងរបាយការណ៍ស៊ើបអង្កេតបន្ថែមផ្សេងៗទៀត។ តែអ្នកស៊ើបអង្កេតក៏ត្រូវតែចង់ចាំដែរថា

ការស៊ើបអង្កេតដែលចាត់ទុកថាចប់សព្វគ្រប់នោះ មិនចាំបាច់លុះត្រាតែធ្វើការចាប់ខ្លួន ល្មើសជននោះទេ។ តែទោះជាយ៉ាងក៏ការស៊ើបអង្កេតត្រូវបានបញ្ចប់ដែរ ទោះជាលទ្ធផលនៃការស៊ើបអង្កេតនោះមិនទាន់ចប់សព្វគ្រប់ក៏ដោយដូចជា ៖

១. ក្រោយពីបានប្រមូលភស្តុតាងទៅនគរបាល ដើម្បីសន្និដ្ឋានថាអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ។

២. ល្មើសជនស្លាប់។

៣. រឿងក្តីនោះជារឿងក្តី ឃាតកម្ម និងអត្តឃាតរបស់ល្មើសជន។

៤. ល្មើសជនសារភាពមុនពេលខ្លួនដាច់ខ្យល់ស្លាប់។

៥. ការចាប់ខ្លួនរបស់ជនសង្ស័យ មិនត្រូវបានជនរងគ្រោះសហការគាំទ្រជាមួយ។

៦. ជនដែលសង្ស័យស្ថិតនៅក្នុងយុត្តាធិការផ្សេង ហើយពិបាកនឹងរកមធ្យោបាយនាំខ្លួនជននោះមកបាន ឬ ក៏អយ្យការយល់ថាការចំណាយដើម្បីនាំខ្លួនជននោះជាការចាំបាច់នោះ។

៧. ជនដែរត្រូវបានចាប់ខ្លួននោះត្រូវបានអយ្យការចោទប្រកាន់លើបទល្មើសដែលនគរបាលចោទដែលទាបជាងបទល្មើសមុន។

### កថាខណ្ឌទី៤ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

បន្ទាប់ពីបានបញ្ចប់នៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធមិ នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ [75] ៖

- បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ
- ដោះលែង ឲ្យមានសេរីភាពឡើងវិញ

សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។

ប្រសិនបើការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធមិត្រូវបានបញ្ចប់ជាស្ថាពរហើយ ព្រមទាំងតម្រុយភស្តុតាងស៊ីសង្វាក់គ្នាទៅនឹងបទល្មើស និងជនសង្ស័យព្រមទាំងផុតរយៈពេល នៃការឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធមិ ត្រូវបញ្ជូលខ្លួនទៅកាន់អយ្យការ។

ក្នុងការបញ្ជូនខ្លួននោះត្រូវគោរពរយៈពេលនៃការបញ្ជូនខ្លួនដូចជា៖

- បើបុគ្គលនោះត្រូវបានបញ្ជូនទៅអយ្យការ ជននោះត្រូវបញ្ជូនទៅភ្លាម
- បើមិនអាចបញ្ជូនដោយមូលហេតុលំបាកក្នុងការដឹកជញ្ជូន ព្រះរាជអាជ្ញាអាចផ្តល់រយៈពេលបន្ថែម
- ការបង្ហាញខ្លួនបុគ្គលឃាត់ខ្លួន ត្រូវធ្វើឡើងក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន។

75. មាត្រា ១០៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌឆ្នាំ ២០០៧

- កំណត់ហេតុអំពីការឃឹតឃាំង ត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌[76]។

76. មាត្រា ១០៤ នៃក្រមនីតិវិធី ព្រហ្មទណ្ឌឆ្នាំ ២០០៧

# ជំពូកទី៣

# ការពិភាក្សាលើលទ្ធផល

# នៃការកោរស្រាចប្រាច

# ជំពូកទី៣
# ការពិភាក្សាលើលទ្ធផលនៃការការស្រាវជ្រាវ

## ផ្នែកទី ១ បញ្ហាប្រឈម

### កថាខណ្ឌទី១ ការចេះសម្របសម្រួលហេសគ្រួបផ្សំ និងការខ្វះសម្ភារៈមធ្យោបាយ

#### ១.១ ការងារមួយចំនួនអសកម្ម

ការងារមួយចំនួនអសកម្ម គឺដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើងបានធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលសភាពការណ៍កើតឡើង។

#### ១.២ ការចាត់តាំងអនុវត្ត

ការចាត់តាំងអនុវត្ត របស់អង្គភាពពាក់ព័ន្ធនៅមានការយឺតយ៉ាវ ខ្វះការទទួលខុសត្រូវ គួបផ្សំនឹងការមិនបានត្រួតពិនិត្យសកម្មភាពការងាររបស់មន្ត្រីគ្រប់ថ្នាក់ឱ្យបានត្រឹមត្រូវ ធ្វើឱ្យប្រសិទ្ធភាពនៃការអនុវត្តផែនការ វិធានមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។

#### ១.៣ ការងារស៊ើបអង្កេត និងការបង្ក្រាប

ការងារស៊ើបអង្កេត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស ការគ្រប់គ្រងមុខសញ្ញានៅក្នុងមូលដ្ឋាន ដូចជា មុខសញ្ញា ក្មេងទំនើងប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញាករណីតស៊ូ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។

#### ១.៤ ការខ្វះមធ្យោបាយ

ការខ្វះមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឱ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឱ្យការងារប្រឆាំងនឹងបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា។ ប៉ុន្តែពេលខ្លះមានមធ្យោបាយខ្វះប្រេង ឬអាគុយខូចជាដើម។

### កថាខណ្ឌទី២ អាណាព្យាបាលរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ នៅក្នុងការបំពេញបេសកម្ម មន្ត្រីនគរបាលយុត្តិធម៌ទទួលបញ្ជា ឬ សុំបញ្ជាតែពីអាជ្ញាធរតុលាការរហូតដល់ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវរាយការណ៍តាមឋានានុក្រមរបស់ខ្លួន អំពីរឿងហេតុកើតឡើងនិងសុំយោបល់ដឹកនាំ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានអាណាព្យាបាលពីរគឺ តាមឋានានុក្រមការងាររដ្ឋបាល ស្ថិតក្រោមការត្រួតពិនិត្យរបស់ស្នងការនគរបាលរាជធានីភ្នំពេញ នៃអគ្គស្នងការរដ្ឋាននគរបាលជាតិ និងការងារនីតិវិធីព្រហ្មទណ្ឌ

ស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញា។

### ២.១ គោលការណ៍ច្បាប់

តាមគោលការណ៍ច្បាប់ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬ ក៏មានការដកពាក្យប្តឹងក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ដែលរក្សាទុកកំណត់ហេតុ ឬ វត្ថុតាងដោយចេតនា ឬ លាក់បំបាំងដល់អាជ្ញាធរតុលាការអំពីអត្ថភាពនៃកំណត់ហេតុ ឬ វត្ថុតាង ត្រូវចាត់ទុកថាមន្ត្រីនគរបាលនោះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

### ២.២ អនុវត្តជាក់ស្តែង

នៅក្នុងការអនុវត្តជាក់ស្តែងជាបទពិសោធន៍មានរឿងមួយបានកើតឡើងចំពោះមន្ត្រីនគរបាលយុត្តិធម៌ ក្រោយពីទទួលបញ្ជាពីថ្នាក់ដឹកនាំឱ្យធ្វើការសម្របសម្រួលបញ្ចប់រឿងទំនាស់មួយ ដោយមានការឯកភាពរវាងជនល្មើស និងជនរងគ្រោះ។ មន្ត្រីនគរបាលយុត្តិធម៌បានរៀបចំសំណុំរឿងមកកាន់ព្រះរាជអាជ្ញា នៅពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿង គាត់ក៏បានពិនិត្យមើលអង្គហេតុ និងអង្គច្បាប់ចប់សព្វគ្រប់ហើយ គាត់យល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាក៏សម្រេចធ្វើការចោទប្រកាន់ បញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ។ ជាលទ្ធផលចុងក្រោយសំណុំរឿង ត្រូវបានបញ្ចប់ជាស្ថាពរនៅស្ថាប័នតុលាការ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ រូបនោះត្រូវបានថ្នាក់ដឹកនាំសម្រួលភារកិច្ច។

## កថាខណ្ឌទី៣ សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ

គោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៦០ បានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[77]។ មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ ចុះដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សី ជនរងគ្រោះ ស្រង់ចម្លើយជនសង្ស័យ និងឃាត់ខ្លួនជនសង្ស័យ ព្រមទាំងធ្វើការឆែកឆេរហូតដល់ចប់កិច្ចប្រតិបត្តិការរៀងៗខ្លួន។ គ្រប់បេសកកម្មរបស់អង្គភាពទាំងពីរមានគោលដៅរួម មានគោលបំណងតែមួយគត់ គឺដើម្បីការពារផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិ អាយុជីវិត ដូច្នេះមិនចាំបាច់ឱ្យគាត់បំពេញភារកិច្ចជាន់គ្នា ដែលនាំឱ្យខាតបង់ពេលវេលា បាត់បង់ថវិការជាតិនោះទេ គឺ គួរតែបែងចែកភារកិច្ចរវាងមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថឱ្យបានច្បាស់លាស់ក្នុងការដើរតួជាមន្ត្រីនគរបាលយុត្តិធម៌។

77 . មាត្រា ៦០ ស្តីពី មន្ត្រីនគរបាលយុត្តិធម៌ នៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ )។

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៨១ បានចង្អុលបង្ហាញពីការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ នៅក្នុងវិស័យនគរបាលយុត្តិធម៌[78]។ ទោះបីជាក្រមនេះ បានចង្អុលបង្ហាញទៅលើអនុក្រឹត្យ ស្តីពីការបែងចែកភារកិច្ចរវាងនគរបាលជាតិ និងកងរាជអាវុធហត្ថក៏ដោយ ប៉ុន្តែរហូតមកដល់ពេលនេះ នៅពុំទាន់ឃើញមានអនុក្រឹត្យ ស្តីពីការកំណត់សមត្ថកិច្ចក្នុងការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌នោះឡើយ។

## ផ្នែកទី២ ដំណោះស្រាយ

### កថាខណ្ឌទី១ យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់

គោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានមនុស្ស និងការបង្កើនសមត្ថភាព វិជ្ជាជីវៈ នៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមរយៈនៃការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ក្រសួងមហាផ្ទៃ បានដាក់ចេញនូវយន្តការកំណែទម្រង់កងកម្លាំងនគរបាលជាតិឱ្យក្លាយជាកងកម្លាំងមួយដែលមានវិជ្ជាជីវៈពិតប្រាកដបំពាក់ដោយបច្ចេកទេសទំនើប មានអត្តចរិតសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវខ្ពស់ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ ដើម្បីអនុវត្តយន្តការនេះ ក្រសួងមហាផ្ទៃបានប្រគល់ភារកិច្ចទៅឱ្យបណ្ឌិតសភានគរបាលកម្ពុជា ធ្វើជាសេនាធិការក្នុងការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិនៅទូទាំងប្រទេស។ ដើម្បីឱ្យបណ្ឌិតសភានគរបាលកម្ពុជា អនុវត្តបានតាមផែនការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទទួលបានជោគជ័យ ត្រូវមានការគាំទ្រពីរាជរដ្ឋាភិបាល ពីក្រសួងមហាផ្ទៃ និងមានការចូលរួមសហការគ្រប់អង្គភាព គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិមានការគាំទ្រ និងមានយន្តការតាមដានចំពោះនិស្សិត សិក្ខាកាម ដែលបណ្ឌិតសភានគរបាលកម្ពុជាបានដាក់ពិន័យ ឬ បណ្តេញចេញពីការសិក្សា។

### កថាខណ្ឌទី២ យន្តការពង្រឹងការអនុវត្តច្បាប់

#### ២.១ ការលុបបំបាត់អំពើពុករលួយ

ជាគោលការណ៍ ការលុបបំបាត់អំពើពុករលួយ នគរបាលយុត្តិធម៌ មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬ កន្លែងប្រព្រឹត្តអំពើអបាយមុខ អំពើពាលាអាវាសែដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួនទៅការពារបទល្មើស ដូចជាការពារជនប្រព្រឹត្ត

78 . មាត្រា ៨១ ស្តីពី ការកំណត់សមត្ថកិច្ច នៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ )។

សកម្មភាព ចាប់ជំរិត លួច ឆក់ ប្លន់កេងប្រវ័ញ្ចសម្បត្តិជាតិ ឬ កេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្រប ច្បាប់។ មិនត្រូវប្រើអំណាចគំរាមគំហែងទៅលើប្រជាពលរដ្ឋ ដើម្បីការពារជនល្មើស និងប្រើប្រាស់ សម្ភាររបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់ ហើយមិនត្រូវលាក់សំណុំរឿង វត្ថុតាង ឬ ធ្វើការដោះដូរនូវវត្ថុតាង ដើម្បីប្រយោជន៍បុគ្គលណាមួយ ឡើយ។

**២.២ ការលុបបំបាត់វប្បធម៌អន្តរាគមន៍**

បរិបទនៃសង្គមខ្មែរបច្ចុប្បន្ន តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ វាគឺជាទម្លាប់ ពលរដ្ឋខ្មែរក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គមទៅហើយ ប៉ុន្តែបញ្ហាទាំងនេះបានក្លាយជាទម្លាប់មិន អាចកែប្រែបាន សូម្បីតែអ្នករត់ម៉ូតូឌុបម្នាក់ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ ពេលដែលខ្លួនត្រូវការជាយថាហេតុ មិនថាមានរឿងរ៉ាវតូច ឬ ធំនោះទេ តែងតែចូលខ្លួនមកដោះ ស្រាយបញ្ចប់បញ្ហា ដោយមិនទុកឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី និងច្បាប់ឡើយ។ អ្នកដែលមាន អំណាច មានឋានៈនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាល យុត្តិធម៌ ដែលធ្វើឱ្យការបំពេញតួនាទីមិនទាន់បានល្អ មិនបានប្រកាន់ភ្ជាប់នូវការអនុវត្តច្បាប់ និងមិន មានយុត្តិធម៌នៅក្នុងសង្គម។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ចរបស់ មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់មូលដ្ឋានគ្រឹះ។ បើមន្ត្រី នគរបាលយុត្តិធម៌ណាម្នាក់ មិនបានប្រតិបត្តិតាមច្បាប់ត្រូវទទួលពិន័យ និងទណ្ឌកម្មជាដាច់ខាត មិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលធ្វើឱ្យមានកំហុសឆ្គងក្នុងការបំពេញ តួនាទីនោះទេ។

**២.៣ ការលុបបំបាត់វប្បធម៌និទណ្ឌភាព**

កាលណាគ្មានយុត្តិធម៌នឹងធ្វើឱ្យមាននិទណ្ឌភាព បើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នា ចំពោះមុខច្បាប់ឡើយ។ និទណ្ឌភាព គឺគ្មានការចាប់ខ្លួន និងនាំខ្លួនជនប្រព្រឹត្តបទល្មើសមកធ្វើការ វិនិច្ឆ័យទោស ពីព្រោះតែមុខតំណែង ឥទ្ធិពល ឬ ទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវបញ្ហា ទាំងនេះ នគរបាលជាតិត្រូវមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ។ នគរបាលយុត្តិធម៌ ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ នៅខណៈពេលដែលខ្លួនបានដឹងពីការប្រព្រឹត្តិបទល្មើស មិនត្រូវរង់ចាំ ឱ្យនរណាម្នាក់ធ្វើពាក្យបណ្ដឹងជាមុននោះទេ មុនពេលដែលខ្លួនចាប់ផ្ដើមស៊ើបអង្កេត។

ជាគោលការណ៍បើមានបទល្មើសព្រហ្មទណ្ឌ កើតឡើង ទោះបីជាគ្មានបណ្ដឹងក៏ដោយ ក៏មន្ត្រី នគរបាលយុត្តិធម៌ត្រូវតែបើកការស៊ើបអង្កេត ស្រាវជ្រាវ ស្វែងរកជនប្រព្រឹត្តបទល្មើស ដើម្បីកសាង សំណុំរឿងបញ្ជូនទៅតុលាការ។ បើមិនដូច្នេះទេ បញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់

តែមានច្រើនឡើងៗ ធ្វើឱ្យសង្គមច្របូកច្របល់ គ្មានសណ្តាប់ធ្នាប់ គ្មានសន្តិភាព ក្លាយទៅជាសង្គមមួយអនាធិបតេយ្យ។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌមួយវា គឺជាសកម្មភាពដ៏សកម្ម ឬ ក៏ជាបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងដំណើរការស៊ើបអង្កេតបទល្មើសនីមួយៗ មន្ត្រីនគរបាលអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែមានតម្រុយមួយចំនួន ឬ ទទួលពាក្យបណ្ដឹងពីជនរងគ្រោះផ្ទាល់ ព្រមទាំងតតិយជន ឬ ក៏អាចជាជនអនាមិកដែលបានរាយការណ៍មកជូនមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់។ បេសកម្មទាំងនោះមានពីរប្រភេទ គឺ ការស៊ើបអង្កេតបទល្មើសជាក់ស្ដែង និងការស៊ើបអង្កេតបឋម។ ការស៊ើបអង្កេតនីមួយៗ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែពិនិត្យឱ្យបានច្បាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ពីព្រោះប្រសិនបើការស៊ើបអង្កេតណាមួយមិនស្របទៅនឹងនីតិវិធីដែលមានចែងក្នុងច្បាប់ទេ ពេលនោះការស៊ើបអង្កេត និងត្រូវទុកជាមោឃៈ។

ការអនុវត្តនៅឧក្រិដ្ឋឋាន ក៏ជាបេសកម្មពិសេសរបស់មន្ត្រីនគរបាលផងដែរ ក្នុងការប្រមែប្រមូលភស្ដុតាង ស្លាកស្នាម ឬ តម្រុយ ដែលអ្វីៗទាំងអស់ គឺជាសញ្ញាដែលឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យបាន។ បេសកម្មនៅកន្លែងកើតហេតុនេះ ត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ ហើយមិនត្រូវឱ្យមានការយឺតយ៉ាវឡើយ។ ព្រោះគុណភាពនៃ ភស្ដុតាងអាចមានការបាត់បង់ដោយសារតែគ្មានការគ្រប់គ្រង ដែលបណ្ដាលមកពីភាពរឹករវដោយសារមានពលរដ្ឋដើរឆ្លងកាត់ធ្វើឱ្យមានការបាត់បង់វត្ថុផ្សេងៗ។ ការបាត់បង់ទាំងនោះ គឺ ជាការបាត់បង់តម្រុយយ៉ាងសំខាន់ក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាល។

បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅរកមុខរកជនដែលបានប្រព្រឹត្តបទល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងសង្គមជាតិ។ មន្ត្រីនគរបាលមិនត្រូវរំលងនូវនីតិវិធីសាកសួរជនសង្ស័យ និងសាក្សីឡើយ ព្រោះវាក៏ជាសញ្ញាមួយដែលអាចឱ្យមន្ត្រីនគរបាលធ្វើការកំណត់អត្តសញ្ញាណជនដែលប្រព្រឹត្តបទល្មើស។ ក្រោយពីស្វែងរកភស្ដុតាងដែលបានបន្សល់ទុកនៅកន្លែងកើតហេតុ ការសម្ភាសន៍ជនសង្ស័យ និងសាក្សីហើយនោះ ប្រសិនបើមានភាពស៊ីសង្វាក់គ្នា ពេលនោះមន្ត្រីនគរបាលអាចចាត់វិធានការតាមស្វែងរកចាប់ខ្លួន ជនដែលបានប្រព្រឹត្តបទល្មើស ដោយមានសេចក្ដីសម្រេចពីព្រះរាជអាជ្ញា ឬ ដោយមានដីកាចាប់ខ្លួនផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការស្រាវជ្រាវរបស់យើងខ្ញុំ ដើម្បីចូលរួមចំណែកធ្វើឱ្យសារណារបស់យើងខ្ញុំមួយនេះអាច យកទៅអនុវត្តន៍បាននៅក្នុងប្រទេសជាតិ ដូច្នេះយើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនមានដូចខាងក្រោមនេះ ៖

- សូមសំណូមពរទៅដល់ប្រជាពលរដ្ឋគ្រប់រូបសូមមេត្តាជួយសហការណ៍គ្នា ជាមួយមន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានបទល្មើសកើតឡើង។ ក្នុងការសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌នោះមានដូចជា ត្រូវតែការរាយការណ៍ផ្តល់ជូនទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានទីតាំងស្ថិតនៅជិតបំផុតនៃកន្លែង ដែលបានកើតហេតុនោះ។
- ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋគ្រប់រូបអាចដាក់ពាក្យបណ្តឹងដោយចំហរ ឬ ក៏ធ្វើជាពាក្យបណ្តឹងអនាមិកក៏បាន ដោយមិនគិតថាប្រជាពលរដ្ឋរូបនោះជាអ្នករងគ្រោះផ្ទាល់ ឬ តតីយជនក្តី គឺមានសិទ្ធិធ្វើពាក្យបណ្តឹងខាងលើ បាន។
- សូមសំណូមពរដល់គ្រប់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ឱ្យលុបបំបាត់ចោល នូវអំពើពុករលួយ ជាពិសេស អ្នកធ្វើកំណត់ហេតុ និងអ្នកធ្វើកោសលវិច្ឆ័យ ដើម្បីជម្រុញឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅដោយយុត្តិធម៌ យ៉ាងល្អបំផុត ជានេះទៅទៀត បានជម្រុញឱ្យប្រទេសជាតិមានតម្លាភាព និងមាននីតិរដ្ឋ។
- សូមឱ្យមន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយមេត្តាគោរពតួនាទី និងច្បាប់ឱ្យបានហ្មត់ចត់នូវក្រមសីលធម៌ ព្រមទាំងគោលការណ៍ទាំងឡាយណាដែលមានចែងក្នុងច្បាប់ឱ្យបានម៉ឺងម៉ាត់ ព្រោះបើមិនបានគោរពទេ នោះអាច និងបណ្តាលឱ្យមានការរំលោភនូវសិទ្ធិមនុស្សព្រមទាំង សិទ្ធិសេរីភាពនឹងសេចក្តីថ្លៃថ្នូររបស់ ប្រជាពលរដ្ឋគ្រប់រូប ថែមទាំងធ្វើឱ្យប្រទេសជាតិ បាត់បង់នូវនីតិរដ្ឋទាំងស្រុងទៀតផង។

# ឯកសារយោង

## ឯកសារយោង

- គេហទំព័រហោសទំព័រហ្វេសប៊ុក (Facebook) គណនីយឈ្មោះ យល់ដឹងអំពីច្បាប់
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ សីហា ២០០៧
- ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៩
- ច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ២២ ឧសភា ២០០៨
- ច្បាប់ស្តីពី "ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៤ តុលាការ ២០០៥
- ច្បាប់ស្តីពី "ព្រៃឈើ ចុះថ្ងៃទី ៣១ សីហា ២០០២
- ប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌"រវាងក្រសួងយុត្តិធម៌ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី៤ កញ្ញា ២០០៨
- ប្រកាសស្តីពី"របៀបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌" របស់ក្រសួងយុត្តិធម៌លេខ២៧ ប្រ.ក រ.ប.ក. ចុះថ្ងៃទី១១ មិថុនា ២០០៤
- សៀវភៅស្តីពី "នគរបាលយុត្តិធម៌" របស់លោកមេធាវី កៅ សីហា ឆ្នាំ២០០៩
- សៀវភៅស្តីពី "បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ នៃកងរាជអាវុធហត្ថ" របស់ ឯកឧត្តម ឧត្តមសេនីយ៍ត្រី អេង ហ៊ី ឆ្នាំ២០១២
- បទប្បញ្ញត្តិស្តីពី"ប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌនិងនីតិព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល។ ចុះថ្ងៃទី១០ ខែកញ្ញា ១៩៩២
- វីឌីអូស្តីពី"កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ" ក្រោមកិច្ចសហប្រតិបត្តិការណ៍ រវាង ក្រសួងយុត្តិធម៌ និងក្រសួងព័ត៌មាន ចុះផ្សាយខែមករា ឆ្នាំ ២០០៨ តាមរយៈទូរទស្សន៍ ទទក
- វីឌីអូស្តីពី"វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌" ក្រោមការធ្វើបទបង្ហាញរបស់ ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ចុះផ្សព្វផ្សាយថ្ងៃទី២០-២៤ មិថុនា ២០១៦
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- សទ្ទានុក្រម រដ្ឋប្បវេណីឆ្នាំ ២០០៧
- លិខិតគំរូស្តីពី "សញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌
- លិខិតគំរូស្តីពី"វិញ្ញាបនបត្របញ្ជាក់ការសិក្សាស្តីពីប៉ូលីសតុលាការ

# ឧបសម្ព័ន្ធទី១

# ក្រមសីលធម៌សំរាប់
# មន្ត្រីប្រតិបត្តិច្បាប់

# Code of Conduct
# for Law Enforcement Officials



# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់
# Code of Conduct for Law Enforcement Officials

*អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃ ទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ ។*

*Adopted by General Assembly resolution 34/169 of 17 December 1979.*

## មាត្រា ១

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក- ពាក្យថា " មន្ត្រីប្រតិបត្តិច្បាប់ " សំដៅដល់មន្ត្រីទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវជ្រើសតាំងក្តី ឱ្យតែប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋ មន្ត្រីទាំងឡាយដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេសនូវសេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច មូលហេតុសង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះជាបន្ទាន់ ។

ឃ- បញ្ញត្តិនេះមានគោលដៅធ្វើការទប់ស្កាត់ មិនត្រឹមតែអំពើហឹង្សា អំពើសាហាវព្រៃផ្សៃ និងការធ្វើទុក្ខទោសដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងធ្វើការទប់ស្កាត់ចំពោះអំពើល្មើសផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏ អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។

## មាត្រា ២

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

***អត្ថាធិប្បាយ :***

ក- សិទ្ធិមនុស្សដូចមានចែងខាងលើ ត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងនោះមានលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួន ដូចជា សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្ដីប្រកាសស្ដីពីការពារជនគ្រប់រូប កុំឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្ដីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្ដីពីការបង្ក្រាប និងផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃពួកអាប៉ាថេដ អនុសញ្ញាអន្តរជាតិស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ហើយនិងមាន អនុសញ្ញាទីក្រុងវីយែនស្ដីពីទំនាក់ទំនងកុងស៊ុល ។

ខ- សេចក្ដីអត្ថាធិប្បាយថ្នាក់ជាតិលើបញ្ញត្តិនេះ គួរបញ្ជាក់ថាជាបទបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលបានទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កំលាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតនៅក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់អាចមានការលើកលែង មានន័យថា មន្ត្រីប្រតិបត្តិច្បាប់ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់កំលាំងតាមការចាំបាច់ និងសមហេតុផល ដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព ឬដើម្បីជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនសង្ស័យតាមច្បាប់ ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។

ខ- តាមធម្មតា ច្បាប់ជាតិនៃប្រទេសនីមួយៗ បានដាក់កំហិតយ៉ាងតឹងតែងដល់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការប្រើប្រាស់កំលាំងនេះ ដោយអនុលោមតាមគោលការណ៍សមាមាត្រ ។ គេក៏ត្រូវយល់ដែរថា គេត្រូវគោរពតាមគោលការណ៍ជាតិស្ដីពីសមាមាត្រក្នុងការបកស្រាយបញ្ញត្តិនេះ ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការបកស្រាយ

បញ្ញត្តិនេះ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំង ដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយឡើយ ។

គ- ការប្រើប្រាស់អាវុធត្រូវបានគេចាត់ទុកថា ជាវិធានការមួយដែលខ្លាំងក្លាបំផុត ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវខំជៀសវាងការប្រើប្រាស់អាវុធ ជាពិសេសទៅលើអនីតិជន ។ ជាទូទៅ ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណាដែលការចាត់វិធានការមិនមានកំលាំងគ្រប់គ្រាន់ ដើម្បីបញ្ឈប់ ឬចាប់ខ្លួនជនល្មើស ។ ពេលណាដែលមានការបាញ់កាំភ្លើងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសំងាត់ ហើយដែលឋិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែរក្សាទុកជាសំងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌ ។

***អត្ថាធិប្បាយ :***

តាមប្រភេទការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលពត៌មានផ្សេងៗ ដែលអាចមានការទាក់ទងដល់ជីវិតរស់នៅផ្ទាល់ខ្លួន ឬដែលអាចបណ្តាលឱ្យខូចខាតដល់ប្រយោជន៍ជាសក្តានុពល ឬជាពិសេសប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការរក្សា និងការប្រើប្រាស់ពត៌មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបានសំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថ៌កំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

## មាត្រា ៥

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ជាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួនដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាម

ធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ [អំពើនេះ] គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស [និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនិងសិទ្ធិមនុស្ស ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :
"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតិយជនណាម្នាក់ ឱ្យផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ ដែលកើតមានដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងករិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុង បទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស " ឡើយ ។

គ- ចំពោះពាក្យថា" ការប្រព្រឹត្ត ឬការធ្វើទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬ ផ្លូវចិត្ត ។

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានាការក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

***អត្ថាធិប្បាយ :***

ក- "ការព្យាបាលជម្ងឺ" សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញវិជ្ជាជីវៈ និងគ្រូពេទ្យជំនួយ ដែលគ្រូពេទ្យទាំងនេះត្រូវធានាឱ្យមានជានិច្ចសំរាប់បំរើសេចក្តីត្រូវការ ។

ខ- ប្រសិនបើបុគ្គលិកផ្នែកសុខាភិបាលចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ ហើយមន្ត្រីប្រតិបត្តិច្បាប់ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលផ្នែកសុខាភិបាលទាំងនេះ នៅពេលដែលគេព្យាបាលជនដែលនៅក្នុងការឃុំគ្រងរបស់ខ្លួន តាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកសុខាភិបាលដែលមិនឋិតក្នុងកិច្ចប្រតិបត្តិការរបស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ- មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវធានាឱ្យមានការព្យាបាលសុខភាពដល់ជនរងគ្រោះ ដោយការរំលោភច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តរំលោភច្បាប់ផងដែរ ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះឱ្យបានយ៉ាងខ្លាំងក្លា ។

***អត្ថាធិប្បាយ :***

ក- អំពើពុករលួយ ក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋពីសំណាក់អាជ្ញាធរដែរ ហើយអំពើបែបនេះជាអំពើដែលផ្ទុយពីកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិច្បាប់ ។ មន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់ មកគ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើ រដ្ឋាភិបាលមិនអាចអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬស្ថាប័នរបស់ខ្លួន ។

ខ- និយមន័យនៃពាក្យ "អំពើពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិ ។ ការរួមគំនិតប្រព្រឹត្តអំពើសូកប៉ាន់ផ្សេងៗ គឺជាបទល្មើសពុករលួយ ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាម ជាមន្ត្រីប្រតិបត្តិច្បាប់ បើមានការ

ព្រមើយកន្ដើយមិនបង្ក្រាបអំពើស្លូកចាន់ឱ្យបានច្បាស់លាស់ទេ មន្ត្រីប្រតិបត្តិច្បាប់ ត្រូវចាត់ទុកថា បានឃុបឃិតក្នុងអំពើពុករលួយដែរ ។ ការទទួលអំណោយ (ជាវត្ថុ ឬជាប្រាក់) រង្វាន់លើកទឹកចិត្តផ្សេងៗ ការសន្យានានា ដែលមិនសមស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទល្មើសពុករលួយ ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវឆន្ទៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យនេះ ហើយត្រូវទប់ស្កាត់ និងប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណា ដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើ ហើយប្រសិនជាចាំបាច់ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

***អត្ថាធិប្បាយ :***

